ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

# សទ្ទានុក្រម
# វិទ្យាសាស្ត្រសេដ្ឋកិច្ច
## ខ្មែរ-អង់គ្លេស-បារាំង

# LEXICON
# OF
# ECONOMICS
## Khmer-English-French

ក្រុមប្រឹក្សាជាតិភាសាខ្មែរ

គណៈកម្មការវិទ្យាសាស្ត្រសេដ្ឋកិច្ច

២០១៩

**បោះពុម្ពលើកទី១** ចំនួន២ ៤០០ច្បាប់
នៅរោងពុម្ព ជី.អ៊ី.ធី.ប៊ីហ្សនេស
ផ្ទះលេខ២៣២០ ផ្លូវ៤៥ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

ក្រុមប្រឹក្សាជាតិភាសាខ្មែរ(ក.ជ.ភ.ខ.)
អាសយដ្ឋាន : មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរសព្ទដៃ : ០១២ ៨៦៣ ៩២០, ០១២ ៥៨៩ ៥៤៩, ០៩២ ៨៩២ ៣៤៣
អ៊ីមែល : ncklofrac@gmail.com
វេបសាយ : www.nckl.gov.kh

# សមាសភាព
# គណៈកម្មការវិទ្យាសាស្ត្រសេដ្ឋកិច្ច
# (ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៤)

| | |
|---|---|
| ១- ឯកឧត្តមបណ្ឌិត ហ៊ាន សាហ៊ីប | ប្រធាន |
| ២- លោកស្រីបណ្ឌិត ព្រុំ ទេវី | អនុប្រធាន |
| ៣- ឯកឧត្តមបណ្ឌិត ហ៊ីង ថូរ៉ាក់ស៊ី | សមាជិក |
| ៤- លោកបណ្ឌិត ឆេង វណ្ណារិទ្ធ | សមាជិក |
| ៥- ឯកឧត្តមបណ្ឌិត ជួរ គារី | សមាជិក |
| ៦- លោក ស៊ូ ម៉ង់ | សមាជិក |
| ៧- លោក ហេង ប៊ុនសុង | សមាជិក |
| ៨- លោក ធឿន សុត្ថា | សមាជិក |
| ៩- លោក សាន ចេង | សមាជិក |
| ១០- លោក ឃឹម វិច្ឆិកា | ជំនួយការខាងភាសា |

# សមាសភាព
# គណៈកម្មការវិទ្យាសាស្ត្រសេដ្ឋកិច្ច
## (ពីខែមករា ឆ្នាំ២០១៤ ដល់ខែតុលា ឆ្នាំ២០១៤)

| | |
|---|---|
| ១- ឯកឧត្តមបណ្ឌិត ហ៊ាន សាហ៊ីប | ប្រធាន |
| ២- លោកស្រីបណ្ឌិត ព្រុំ ទេវី | អនុប្រធាន |
| ៣- ឯកឧត្តមបណ្ឌិត ហ៊ីង ថូរ៉ាក់ស៊ី | សមាជិក |
| ៤- លោកបណ្ឌិត ឆេង វណ្ណារិទ្ធ | សមាជិក |
| ៥- ឯកឧត្តមបណ្ឌិត ជួរ គារី | សមាជិក |
| ៦- លោក ស៊ូ ម៉ង់ | សមាជិក |
| ៧- លោក ហេង ប៊ុនសុង | សមាជិក |
| ៨- លោក ធឿន សុត្ថា | សមាជិក |
| ៩- លោក សាន ចេង | សមាជិក |
| ១០- លោក គឹម វុទ្ធី | សមាជិក |
| ១១- លោក ឃឹម វិច្ឆិកា | ជំនួយការខាងភាសា |

# សមាសភាព

# គណៈកម្មការវិទ្យាសាស្ត្រសេដ្ឋកិច្ច

## (ពីខែវិច្ឆិកា ឆ្នាំ២០១៤ ដល់ខែកក្កដា ឆ្នាំ២០១៥)

| | | |
|---|---|---|
| ១- ឯកឧត្តមបណ្ឌិត | ហ៊ាន សាហ៊ីប | ប្រធាន |
| ២- លោកស្រីបណ្ឌិត | ព្រុំ ទេវី | អនុប្រធាន |
| ៣- ឯកឧត្តមបណ្ឌិត | ហ៊ីង ថូរ៉ាក់ស៊ី | អនុប្រធាន |
| ៤- លោកបណ្ឌិត | ឆេង វណ្ណារិទ្ធ | សមាជិក |
| ៥- ឯកឧត្តមបណ្ឌិត | ជួរ គារី | សមាជិក |
| ៦- លោក | ស៊ូ ម៉ង់ | សមាជិក |
| ៧- លោក | ហេង ប៊ុនសុង | សមាជិក |
| ៨- លោក | ធឿន សុត្ថា | សមាជិក |
| ៩- លោក | សាន ចេង | សមាជិក |
| ១០- លោក | គឹម វុទ្ធី | សមាជិក |
| ១១- លោក | អ៊ឹម សុខជី | សមាជិក |
| ១២- លោក | ម៉ន វុត្ថា | សមាជិក |
| ១៣- លោក | ឃឹម វិច្ឆិកា | ជំនួយការខាងភាសា |

# សមាសភាព
# គណៈកម្មការវិទ្យាសាស្ត្រសេដ្ឋកិច្ច
# (ពីខែកញ្ញា ឆ្នាំ២០១៥ ដល់ខែតុលា ឆ្នាំ២០១៧)

| | | |
|---|---|---|
| ១- ឯកឧត្តមបណ្ឌិត | ហ៊ាន សាហ៊ីប | ប្រធាន |
| ២- លោកស្រីបណ្ឌិត | ព្រុំ ទេវី | អនុប្រធាន |
| ៣- ឯកឧត្តមបណ្ឌិត | ហ៊ីង ថូរ៉ាក់ស៊ី | អនុប្រធាន |
| ៤- លោកបណ្ឌិត | ឆេង វណ្ណារិទ្ធ | សមាជិក |
| ៥- ឯកឧត្តមបណ្ឌិត | ជួរ គារី | សមាជិក |
| ៦- លោក | ស៊ូ ម៉ង់ | សមាជិក |
| ៧- លោក | ហេង ប៊ុនសុង | សមាជិក |
| ៨- លោក | ធឿន សុត្ថា | សមាជិក |
| ៩- លោក | សាន ចេង | សមាជិក |
| ១០- លោក | ម៉ន វុត្ថា | សមាជិក |
| ១១- លោក | អ៊ឹម សុខជី | សមាជិក |
| ១២- លោក | គី សេរីវឌ្ឍន៍ | សមាជិក |
| ១៣- លោក | ឃឹម វិច្ឆិកា | ជំនួយការខាងភាសា |

# សមាសភាព
# គណៈកម្មការវិទ្យាសាស្ត្រសេដ្ឋកិច្ច
# (ពីខែវិច្ឆិកា ឆ្នាំ២០១៧ ដល់ខែមករា ឆ្នាំ២០១៨)

| | |
|---|---|
| ១- លោកស្រីបណ្ឌិត ព្រុំ ទេវី | ប្រធាន |
| ២- ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ីង ថូរ៉ាក់ស៊ី | អនុប្រធាន |
| ៣- លោកបណ្ឌិត ឆេង វណ្ណារិទ្ធ | សមាជិក |
| ៤- លោកបណ្ឌិត គី សេរីវឌ្ឍន៍ | សមាជិក |
| ៥- ឯកឧត្តម សារុន រ៉ាឌី | សមាជិក |
| ៦- លោកបណ្ឌិត មិន ប្រុសបញ្ញារិទ្ធិ | សមាជិក |
| ៧- លោក ស៊ូ ម៉ង់ | សមាជិក |
| ៨- លោក ហេង ប៊ុនសុង | សមាជិក |
| ៩- លោក ធឿន សុត្ថា | សមាជិក |
| ១០- លោក ម៉ន វុត្ថា | សមាជិក |
| ១១- លោកស្រី កែវ ខេមរា | សមាជិក |
| ១២- លោកបណ្ឌិត ឈឹម ផាន់ណា | សមាជិក |
| ១៣- លោកបណ្ឌិត ហុង វណ្ណៈ | សមាជិក |
| ១៤- លោក ឃឹម វិច្ឆិកា | ជំនួយការខាងភាសា |

# សមាសភាព
# គណៈកម្មការវិទ្យាសាស្ត្រសេដ្ឋកិច្ច
# (ពីខែកុម្ភៈ ឆ្នាំ២០១៨ ដល់ខែមេសា ឆ្នាំ២០១៨)

| | |
|---|---|
| ១- លោកស្រីបណ្ឌិត ព្រុំ ទេវី | ប្រធាន |
| ២- ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ីង ថូរ៉ាក់ស៊ី | អនុប្រធាន |
| ៣- លោកបណ្ឌិត ឆេង វណ្ណារិទ្ធ | សមាជិក |
| ៤- លោកបណ្ឌិត គី សេរីវឌ្ឍន៍ | សមាជិក |
| ៥- លោកបណ្ឌិត មិន ប្រុសបញ្ញារិទ្ធិ | សមាជិក |
| ៦- លោក ស៊ូ ម៉ង់ | សមាជិក |
| ៧- លោក ហេង ប៊ុនសុង | សមាជិក |
| ៨- លោក ធឿន សុត្ថា | សមាជិក |
| ៩- លោក ម៉ន វុត្ថា | សមាជិក |
| ១០- លោកស្រី កែវ ខេមរា | សមាជិក |
| ១១- លោកបណ្ឌិត ឈឹម ផាន់ណា | សមាជិក |
| ១២- លោកបណ្ឌិត ហុង វណ្ណៈ | សមាជិក |
| ១៣- លោក ឃឹម វិច្ឆិកា | ជំនួយការខាងភាសា |

# សមាសភាព
# គណៈកម្មការវិទ្យាសាស្ត្រសេដ្ឋកិច្ច
# (ពីខែឧសភា ឆ្នាំ២០១៨ ដល់បច្ចុប្បន្ន)

| | |
|---|---|
| ១- លោកស្រីបណ្ឌិត ព្រុំ ទេវី | ប្រធាន |
| ២- ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ីង ថូរ៉ាក់ស៊ី | អនុប្រធាន |
| ៣- លោកបណ្ឌិត ឆេង វណ្ណារិទ្ធ | សមាជិក |
| ៤- លោកបណ្ឌិត គី សេរីវឌ្ឍន៍ | សមាជិក |
| ៥- លោកបណ្ឌិត មិន ប្រុសបញ្ញារិទ្ធិ | សមាជិក |
| ៦- លោក ស៊ូ ម៉ង់ | សមាជិក |
| ៧- លោក ហេង ប៊ុនសុង | សមាជិក |
| ៨- លោក ធឿន សុត្ថា | សមាជិក |
| ៩- លោក ម៉ន វុត្ថា | សមាជិក |
| ១០- លោកស្រី កែវ ខេមរា | សមាជិក |
| ១១- លោកបណ្ឌិត ឈឹម ផាន់ណា | សមាជិក |
| ១២- លោកបណ្ឌិត ហុង វណ្ណៈ | សមាជិក |
| ១៣- លោកបណ្ឌិត ឃិន ឆេងស៊ន | សមាជិក |
| ១៤- លោក ឃឹម វិច្ឆិកា | ជំនួយការខាងភាសា |

# បុព្វកថា

ក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.) នៃរាជបណ្ឌិត្យសភាកម្ពុជាមានភារកិច្ចស្វែងរកឯកភាពជូនភាសាខ្មែរ ទាំងអក្ខរាវិរុទ្ធ ទាំងអំណាន និងពាក្យពេចន៍។ ទន្ទឹមនឹងការស្វែងរកឯកភាពនេះ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក៏មានតួនាទីបង្កើតបច្ចេកសព្ទថ្មីៗដែលទាក់ទងនឹងជំនាញផ្សេងៗផងដែរ។

វិស័យសេដ្ឋកិច្ចជាវិស័យចម្បងមួយក្នុងការអភិវឌ្ឍសង្គមជាតិ។ ការសិក្សាស្រាវជ្រាវនិងចែករំលែកចំណេះដឹងអំពីបញ្ហានិងជំនាញសេដ្ឋកិច្ច គឺជាសារៈសំខាន់មួយ និងតម្រូវឱ្យមានបច្ចេកសព្ទសម្រាប់ប្រើប្រាស់ក្នុងភាសាខ្មែរជាចាំបាច់។ កន្លងមក ឥស្សរជនដែលមានចំណេះដឹងជំនាញខាងវិស័យសេដ្ឋកិច្ច បានបង្កើតបច្ចេកសព្ទសេដ្ឋកិច្ច និងប្រើប្រាស់តាមលទ្ធភាពនិងតម្រូវការរៀងៗខ្លួន។

បច្ចេកសព្ទសេដ្ឋកិច្ចដែលស្នើដោយគណៈកម្មការវិទ្យាសាស្ត្រសេដ្ឋកិច្ច ហើយត្រូវបានប្រជុំអនុម័តដោយក្រុមប្រឹក្សាជាតិភាសាខ្មែរ និងបានបោះពុម្ពផ្សាយក្នុងសទ្ទានុក្រមនេះ ពិតជាមានសារៈសំខាន់ណាស់សម្រាប់ប្រើប្រាស់ក្នុងការសិក្សានិងស្វែងយល់ពីវិទ្យាសាស្ត្រសេដ្ឋកិច្ចជាភាសាខ្មែរ និងរួមចំណែកយ៉ាងធំធេងក្នុងការស្វែងរកឯកភាពជូនភាសាជាតិយើង។

ថ្ងៃចន្ទ ៦កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩

**ប្រធានរាជបណ្ឌិត្យសភាកម្ពុជា**

បណ្ឌិតសភាចារ្យ **សុខ ទូច**

# អារម្ភកថា

គណៈកម្មការបច្ចេកទេសទាំង១៧ នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ(ក.ជ.ភ.ខ.) មានភារកិច្ចស្រាវជ្រាវ ចងក្រង និងបង្កើតពាក្យទៅតាមជំនាញរៀងៗខ្លួន។ គណៈកម្មការបច្ចេកទេសនីមួយៗបានស្នើបច្ចេកសព្ទរបស់ខ្លួននៅក្នុងការប្រជុំអនុម័តពាក្យរបស់ ក.ជ.ភ.ខ.។ ពាក្យដែលបានអនុម័តរួចត្រូវបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្ររបស់ ក.ជ.ភ.ខ. ហើយបន្ទាប់មក ពាក្យទាំងនោះត្រូវបានប្រមូលចងក្រងដើម្បីបោះពុម្ពជាសទ្ទានុក្រម។

វិស័យសេដ្ឋកិច្ចជាវិស័យចម្បងមួយក្នុងការអភិវឌ្ឍសង្គម។ ដើម្បីឆ្លើយតបនឹងការរីកចម្រើននៃវិស័យសេដ្ឋកិច្ច បច្ចេកសព្ទថ្មីៗជាច្រើនក្នុងវិស័យនេះត្រូវបានឥស្សរជនដែលមានចំណេះដឹងនិងជំនាញពាក់ព័ន្ធ ខិតខំស្រាវជ្រាវ ចងក្រង និងបង្កើតឡើង ដើម្បីប្រើប្រាស់ទៅតាមតម្រូវការចាំបាច់នាពេលបច្ចុប្បន្ន។

នៅឆ្នាំ២០១៥ គណៈកម្មការវិទ្យាសាស្ត្រសេដ្ឋកិច្ចបានស្នើអនុម័តបច្ចេកសព្ទលើកទី១ បានចំនួន៨៣ពាក្យ ហើយនៅឆ្នាំ២០១៨ គណៈកម្មការនេះស្នើអនុម័តបច្ចេកសព្ទលើកទី២ បានចំនួន១២៣ពាក្យ។ ក្រៅពីបច្ចេកសព្ទដែលបានស្នើអនុម័តទាំងពីរលើកដោយគណៈកម្មការវិទ្យាសាស្ត្រសេដ្ឋកិច្ច លេខាធិការដ្ឋាននៃ ក.ជ.ភ.ខ. ក៏បានបញ្ចូលពាក្យសេដ្ឋកិច្ចដែលស្នើដោយមជ្ឈដ្ឋានខាងក្រៅចំនួន៣០ពាក្យបន្ថែមទៀត។ ដូច្នេះ នៅក្នុងសទ្ទានុក្រមនេះ មានបច្ចេកសព្ទសរុបចំនួន២៣៦ពាក្យ។

ក.ជ.ភ.ខ. សង្ឃឹមថា សទ្ទានុក្រមវិទ្យាសាស្ត្រសេដ្ឋកិច្ចនេះ ជាវិភាគទានមួយដ៏សំខាន់សម្រាប់សាធារណជនយកទៅប្រើប្រាស់តាមតម្រូវការដើម្បីអភិវឌ្ឍចំណេះដឹង និងជួយសម្រួលដល់ការប្រើប្រាស់បច្ចេកសព្ទនៃជំនាញនេះឱ្យឯកភាពគ្នាទាំងអក្ខរាវិរុទ្ធនិងន័យផងដែរ។

ក.ជ.ភ.ខ. មិនអាចដំណើរការបានទេ បើគ្មានការគាំទ្រនិងការលើកទឹកចិត្តពីសំណាក់រាជរដ្ឋាភិបាល។ អាស្រ័យហេតុនេះ ក្នុងនាម ក.ជ.ភ.ខ. ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំរាជរដ្ឋាភិបាលដែលបានឧបត្ថម្ភគាំទ្រដល់ ក.ជ.ភ.ខ. យើង ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត។

ថ្ងៃចន្ទ ៧រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩

**ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ**

បណ្ឌិត **ហ៊ាន សុខុម**

# ក

**កម្ចី**
អ. loan
បារ. emprunt ( m. )

ប្រាក់ឬទំនិញដែលបានខ្ចីហើយត្រូវទូទាត់សងវិញតាមលក្ខខណ្ឌនៃកិច្ចសន្យា។

**កម្មភាព**
អ. employment
បារ. employ ( m. )

ភាពមានការងារធ្វើកើតឡើងក្នុងស្ថានភាពដែលមនុស្សម្នាក់គ្រប់អាយុធ្វើការ មានសមត្ថភាព មានបំណងធ្វើការស្វះស្វែងរកការងារធ្វើនិងអាចរកការងារធ្វើបាន។

ឧ. រាជរដ្ឋាភិបាលមានគោលនយោបាយទាក់ទាញ និងផ្តល់ការលើកទឹកចិត្តដល់វិស័យឯកជនឱ្យវិនិយោគ ដើម្បីបង្កើនអត្រាកម្មភាព។

**កម្មសិទ្ធិ**
អ. property rights / ownership
បារ. propriété ( f. )

សិទ្ធិពេញលេញជាម្ចាស់លើទ្រព្យ។ សិទ្ធិនេះរួមបញ្ចូលទាំងសិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យផល និងសិទ្ធិចាត់ចែងលើទ្រព្យ។

**កម្មសិទ្ធិករ**
អ. owner
បារ. propriétaire ( n. )

រូបវន្តបុគ្គលឬនីតិបុគ្គលដែលមានសិទ្ធិពេញលេញជាម្ចាស់កម្មសិទ្ធិលើទ្រព្យ។

**កម្រៃជើងសា**
អ. commission
បារ. commission ( f. )

ភាគរយនៃថ្លៃទំនិញឬអត្ថប្រយោជន៍( ទំនិញ របស់ប្រាក់...) ដែលភ្នាក់ងារទិញលក់ឬ ភ្នាក់ងារដទៃទៀតត្រូវបានទទួលក្នុងទំនាក់ទំនងការងារនោះ។

**កម្លាំងចលករ**
អ. driving force
បារ. force mortice

គោលនយោបាយ វិធានការ ឬ កម្លាំង (ចំណេះដឹង សមត្ថភាពគ្រប់គ្រងកម្លាំង ពលកម្ម បច្ចេកវិទ្យា...) ដែលមានឥទ្ធិពលឬជំរុញឱ្យមានលំនឹងឬកំណើនសេដ្ឋកិច្ច។

ឧ. គោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ជាកម្លាំងចលករដែលជំរុញឱ្យអង្ករកម្ពុជាមានទីផ្សារកាន់តែធំទូលាយ និងមានភាពប្រកួតប្រជែងនៅលើទីផ្សារអង្ករពិភពលោក។

**កម្លាំងពលកម្ម**
អ. labor force
បារ. force de travail

ក្រុមមនុស្សដែលមានការងារធ្វើនិងកំពុងស្វែងរកការងារធ្វើនៅក្នុងប្រទេសមួយឬតំបន់មួយ ក្នុងរយៈពេលមួយជាក់លាក់។

កម្លាំងពលកម្មគឺជាជាតុមួយដ៏សំខាន់នៃកត្តាផលិតកម្មរបស់ប្រទេសមួយ។

ឧ. វិស័យវាយនភណ្ឌនិងកាត់ដេរសម្លៀកបំពាក់នៅ

កម្ពុជាបានស្រូបយកកម្លាំងពលកម្មជាច្រើនពីទីជនបទ។

**កលិយុគ**
អ. turmoil
បារ. trouble ( m. )

ភាពចលាចល ឬ ភាពរំជើបរំជួលនៃស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
ឧ. អ្នកវិភាគមានការព្រួយបារម្ភថា សេដ្ឋកិច្ចដែលពឹងផ្អែកលើការផលិតប្រេង អាចប្រឈមនឹងកលិយុគនៅពេលដែលតម្លៃប្រេងនិងឧស្ម័នធ្លាក់ចុះ។

**កសិកម្មតាមកិច្ចសន្យា**
អ. contract farming

ផលិតកម្មកសិកម្មផ្អែកលើកិច្ចសន្យារវាងអ្នកផលិតនិងអ្នកទិញកសិផលដែលបានព្រមព្រៀងគ្នាទៅលើបរិមាណផ្គត់ផ្គង់ គុណភាពកសិផល ថ្លៃកសិផល ពេលវេលា ទិញ លក់ ការផ្តល់បច្ចេកទេស ពូជ ជី ដើមទុន ជាដើម។

**កាតាលីករ**
អ. catalyst
បារ. catalyseur ( m. )

យន្តការ ប្រព័ន្ធ កម្មវិធី គម្រោង សកម្មភាព ឬកិច្ចព្រមព្រៀងដែលជំរុញឱ្យសកម្មភាពសេដ្ឋកិច្ច ឬធុរកិច្ចមួយអាចឈានដល់គោលដៅឆាប់រហ័សជាងមុន។
ឧ. ការជំរុញបង្កើតឱ្យមានតំបន់សេដ្ឋកិច្ចពិសេសជាកាតាលីករធ្វើឱ្យការវិនិយោគផ្ទាល់ពីបរទេសហូរចូលមកកម្ពុជាកាន់តែច្រើនឡើង។

**ការជួល**
អ. rent
បារ. location (f.)

កិច្ចព្រមព្រៀងជួលរវាងកម្មសិទ្ធិករនិងអ្នកជួលតាមលក្ខខណ្ឌដែលបានកំណត់។

**ការបង្ហាញជាសាធារណៈ**
អ. road show

យុទ្ធនាការបង្ហាញរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រដើម្បីទាក់ទាញការចាប់អារម្មណ៍របស់វិនិយោគិនដែលមានសក្តានុពលនិងសាធារណជនទូទៅ និងដើម្បីបង្កើតតម្រូវការចំពោះមូលបត្រដែលត្រូវបោះផ្សាយជាសាធារណៈលើកដំបូង។

**ការផុសឡើង**
អ. emergence
បារ. émergence (f.)

ការលេចឡើង ឬ ការចាប់ផ្តើមបង្ហាញពីសក្តានុពលសេដ្ឋកិច្ចរបស់ប្រទេសឬតំបន់ដែលទើបមានកំណើនសេដ្ឋកិច្ចខ្ពស់មិនធ្លាប់មានពីមុនមកដោយសារការរីកចម្រើននៃពាណិជ្ជកម្ម ឧស្សាហកម្ម សំណង់ ទេសចរណ៍។ល។

**ការផ្ទុះឡើង**
អ. boom
បារ. boom (m.)

ដំណើររីកចម្រើនខ្លាំង ដំណើរលូតលាស់ខ្លាំង ដំណើរស្ទុះឡើង ឬ កំណើនយ៉ាងឆាប់រហ័សនៃសេដ្ឋកិច្ចក្នុងមួយរយៈពេលដ៏ខ្លី។
សន្ទុះសេដ្ឋកិច្ចសំដៅលើការកើនឡើងនូវផលិតភាពការលក់ ប្រាក់ឈ្នួល និងតម្រូវការកើនឡើងក្នុងរយៈពេលមួយដ៏ខ្លី។

៤. ការផ្ទុះឡើងនៃសេដ្ឋកិច្ចពិភពលោកនៅអំឡុងដើមឆ្នាំ១៩២០ បានស្តែងឡើងតាមរយៈកំណើននៃផលិតផលក្នុងស្រុកសរុប ផលិតកម្ម និង កម្រិតជីវភាពរស់នៅ។

**ការិយាល័យតំណាងធនាគារបរទេស**
អ. foreign bank representative office
បារ. bureau représentant de banque étrangère

ទីភ្នាក់ងារតំណាងរបស់ធនាគារបរទេសមានមុខងារស្រាវជ្រាវទីផ្សារ ទាក់ទងអតិថិជន ទាក់ទាញវិនិយោគិន និង មិនធ្វើប្រតិបត្តិការធនាគារដោយផ្ទាល់។

**ការិយាល័យឥណទាន**
អ. credit bureau
បារ. bureau de crédit

ក្រុមហ៊ុនផ្តល់ព័ត៌មានហិរញ្ញវត្ថុ ឧបករណ៍វិភាគទិន្នន័យ និង របាយការណ៍ឥណទានទៅដល់គ្រឹះស្ថានហិរញ្ញវត្ថុ។

**កាលានុវត្តភាព**
អ. opportunity
បារ. opportunité ( f. )

កាលៈទេសៈដ៏សមគួរឬដំណើរវិវឌ្ឍត្រូវពេលវេលាឱកាសដែលអនុគ្រោះសម្រាប់ចាប់យកប្រយោជន៍អំពីកិច្ចការអ្វីមួយ ឬ គុណសម្បត្តិអ្វីមួយដែលកំពុងលេចឡើង ក៏ប៉ុន្តែ ការទាញយកប្រយោជន៍នោះគឺអាចប្រឈមនឹងហានិភ័យហើយចាំបាច់ត្រូវប្តេជ្ញាចិត្តយ៉ាងមុតមាំ និង មានធនធានគ្រប់គ្រាន់ទើប

គេអាចទាញយកប្រយោជន៍នោះបាន។
ឧ. វិបត្តិសេដ្ឋកិច្ចពិភពលោកឆ្នាំ២០០៨-២០០៩ ផ្ដល់កាលានុវត្តភាពដល់កម្ពុជាសម្រាប់អភិវឌ្ឍវិស័យកសិកម្មដ៏មានសក្ដានុពលរបស់ខ្លួន។ ដើម្បីសម្រេចកិច្ចការនេះ កម្ពុជាត្រូវការទាំងធនធានមនុស្សទាំងធនធានហិរញ្ញវត្ថុយ៉ាងច្រើនសន្ធឹកសន្ធាប់សម្រាប់វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តចាំបាច់របស់ខ្លួន។ ក្នុងន័យសេដ្ឋកិច្ចប្រើផ្សំនឹងថ្លៃដើម( opportunity cost) ពាក្យនេះមានន័យថាជាថ្លៃដើមកាលានុវត្តភាព ដែលសំដៅដល់ថ្លៃដើមនៃជម្រើសល្អផ្សេងទៀតដែលត្រូវបានបោះបង់ចោល។

ពាក្យនេះ ប្រើក្នុងគោលដៅធានាឱ្យបាននូវប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានដែលមាន។

កាលានុវត្តភាពក្នុងកាលៈទេសៈខ្លះអាចត្រូវបានគេប្រើជាវេវចនសព្ទជាមួយនឹងពាក្យ«ឱកាស»ប៉ុន្តែជាទូទៅ គេប្រើពាក្យ«ឱកាស»សម្រាប់បញ្ជាក់ពីពេលវេលាឬកាលៈទេសៈធម្មតាប៉ុណ្ណោះ។
ឧ. ថ្ងៃនេះមេឃស្រឡះល្អ។ ដូច្នេះវាជាឱកាសល្អសម្រាប់កសិករហាលស្រូវអង្ករបស់ខ្លួន។

**កិច្ចទីផ្សារ/ម៉ាឃិធីង**
អ. marketing
បារ. marketing (m.)

សំណុំនៃសកម្មភាពបុគ្គល ស្ថាប័ន ឬ ក្រុមហ៊ុននានាក្នុងការបង្កើតតម្លៃ ការផ្សព្វផ្សាយ ការជំរុញ ការដោះដូរ និងការផ្តល់នូវអ្វីដែលមានប្រយោជន៍ដល់អតិថិជន ដៃគូ និងសង្គមទាំងមូល។

**កិច្ចទីផ្សារការី/ការីម៉ាឃិធីង**
អ. marketer
បារ. marketeur (m.)

អ្នករៀបចំនិងអនុវត្តយុទ្ធនាការកិច្ចទីផ្សារ។

**កិច្ចទីផ្សារចម្រុះ/ម៉ាឃិធីងចម្រុះ**
អ. marketing mix
បារ. marketing mix

មធ្យោបាយកិច្ចទីផ្សារឬម៉ាឃិធីងទាំងឡាយដែលសហគ្រាសប្រើប្រាស់ ដើម្បីសម្រេចនូវការលក់ផលិតផលរបស់ខ្លួននៅទីផ្សារគោលដៅ។

ជាតុនៃកិច្ចទីផ្សារចម្រុះឬម៉ាឃិធីងចម្រុះ ជាទូទៅមានបួនគឺ ផលិតផល (Product) ថ្លៃ(Price) ទីកន្លែង(Place) និង ការជំរុញផ្សព្វផ្សាយ (Promotion)ដែលហៅថា Pបួន "Four Ps"។

**កិច្ចទីផ្សារចល័ត/ ម៉ាឃិធីង ចល័ត**
អ. mobile marketing
បារ. marketing mobile

សំណុំសកម្មភាពកិច្ចទីផ្សារដើម្បីផ្សព្វផ្សាយអំពីផលិតផលដល់អតិថិជនតាមរយៈឧបករណ៍ចល័តរបស់អ្នកទទួល។

**កិច្ចទីផ្សារឌីជីថល/ ឌីជីថលម៉ាឃិធីង**

អ. digital marketing

បារ. marketing numérique

សំណុំសកម្មភាពកិច្ចទីផ្សារដើម្បីផ្សព្វផ្សាយអំពីផលិតផលដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។

**កិច្ចសម្រួលពាណិជ្ជកម្ម**

អ. trade facilitation

ការធ្វើឱ្យដំណើរការពាណិជ្ជកម្មអន្តរជាតិមានភាពសាមញ្ញ កាន់តែងាយស្រួល និងមានសុខដុមនីយកម្មតាមរយៈគោលការណ៍ វិធានការ អភិក្រម ឬនីតិវិធី។ល។

**កុំម៉ូឌីធី**

អ. commodities

វត្ថុធាតុដើមឬផលិតផលកសិកម្មបឋមដែលអាចទិញឬលក់នៅលើទីផ្សារ។

**កូនបំណុល**

អ. debtor

បារ. débiteur ( m. )

បុគ្គលដែលត្រូវសងបំណុល។

**ក្រុមហ៊ុនពាណិជ្ជកម្មបរទេស**
អ. foreign commercial company
បារ. société commerciale étrangère

ក្រុមហ៊ុនដែលបង្កើតឡើងក្រោមច្បាប់នៃប្រទេសណាមួយ ហើយបានបោះទីតាំងធ្វើពាណិជ្ជកិច្ចនៅក្រៅប្រទេសនោះ។

**ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ**
អ. financial leasing company
បារ. société de bail financier

នីតិបុគ្គលដែលផ្តល់ជូនអតិថិជននូវការប្រើប្រាស់និងអាស្រ័យផលពីចលនវត្ថុណាមួយដោយយកថ្លៃឈ្នួល។

**ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត**
អ. public limited company ( PLC )
បារ. société anonyme ( S.A )

ក្រុមហ៊ុនមូលធនមួយប្រភេទបង្កើតឡើងនិងចុះបញ្ជីតាមច្បាប់ ដឹកនាំ និងគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាល ដែលក្នុងនោះមានសមាសភាពជាអភិបាលយ៉ាងតិច៣រូប។ ក្រុមហ៊ុនប្រភេទនេះមានសិទ្ធិបោះចេញនូវមូលបត្រ សម្រាប់លក់ជាសាធារណៈ។ ម្ចាស់ភាគហ៊ុនម្នាក់ៗទទួលខុសត្រូវចំពោះបំណុលក្រុមហ៊ុនត្រឹមតែចំនួនភាគហ៊ុនដែលខ្លួនមានក្នុងក្រុមហ៊ុនប៉ុណ្ណោះ។

**ក្រុមហ៊ុនមូលធន**
អ. limited company

ក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត បង្កើតដោយលក្ខន្តិកៈនិងជានីតិបុគ្គលដាច់ដោយឡែកពីម្ចាស់ភាគហ៊ុន ហើយម្ចាស់ភាគហ៊ុនទទួលខុសត្រូវត្រឹមចំនួនភាគហ៊ុនដែលខ្លួនបានទិញ។ ក្រុមហ៊ុននេះគ្រប់គ្រងនិងដឹកនាំដោយក្រុមប្រឹក្សាភិបាល។

**ក្រុមហ៊ុនសហកម្មសិទ្ធិ**
អ. partnership
បារ. société de personnes

ក្រុមហ៊ុនទទួលខុសត្រូវគ្មានកម្រិត បង្កើតឡើងដោយកិច្ចសន្យា ដែលមានបុគ្គល២នាក់ឡើងទៅនិងជានីតិបុគ្គលដែលមិនដាច់ដោយឡែកពីម្ចាស់។ ក្រុមហ៊ុននេះគ្រប់គ្រងដោយសហកម្មសិទ្ធិករទូទៅទាំងអស់។

**ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ**
អ. general partnership
បារ. société en nom collectif ( SNC )

ក្រុមហ៊ុនសហកម្មសិទ្ធិមួយប្រភេទដែលកើតឡើងពីកិច្ចសន្យារវាងបុគ្គល២ឬច្រើននាក់ ដែលដាក់រួមគ្នានូវទ្រព្យសម្បត្តិ ចំណេះដឹង ឬ សកម្មភាពរបស់បុគ្គលទាំងនោះ ដើម្បីប្រកបពាណិជ្ជកិច្ចរួមក្នុងគោលបំណងរកប្រាក់ចំណេញ ហើយសមាជិកទាំងអស់ជាសហកម្មសិទ្ធិករទូទៅ។

**ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត**

អ. limited partnership

បារ. société en commandite

ក្រុមហ៊ុនសហកម្មសិទ្ធិមួយប្រភេទដែលកើតឡើងពីកិច្ចសន្យារវាងសហកម្មសិទ្ធិករទូទៅម្នាក់ឬច្រើននាក់ ដែលមានបុគ្គលម្នាក់ត្រូវបានអនុញ្ញាតឱ្យគ្រប់គ្រងនិងមានកាតព្វកិច្ចនៅក្នុងក្រុមហ៊ុនជាមួយសហកម្មសិទ្ធិករមានកម្រិតម្នាក់ឬច្រើននាក់ទៀត ដែលមានកាតព្វកិច្ចបង់ភាគទុនចូលទៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិនោះ។

**ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត (ឯ.ក)**

អ. private limited company ( Co., Ltd )

បារ. société à responsabilité limitée ( SARL )

ក្រុមហ៊ុនមូលធនមួយប្រភេទដែលបង្កើតឡើងនិងចុះបញ្ជីតាមច្បាប់ មានសមាជិកភាគហ៊ុនចាប់ពី២នាក់រហូតដល់៣០នាក់ ហើយសមាជិកម្នាក់ៗទទួលខុសត្រូវចំពោះបំណុលក្រុមហ៊ុនត្រឹមតែចំនួនភាគហ៊ុនដែលខ្លួនបានដាក់ដើមទុនក្នុងក្រុមហ៊ុនប៉ុណ្ណោះ និង មិនអាចលក់ភាគហ៊ុនជាសាធារណៈបាន។

# ខ

**ខិត្តបណ្ណ**
អ. notice-leaf
បារ. tract (m.)

បណ្ណក្រដាសបោះពុម្ពឡើងដើម្បីផ្សព្វផ្សាយដំណឹងឱ្យប្រជាជនអនុវត្តតាម ច្រើនបាចពីយន្តហោះ ឬបោះពុម្ពដោយក្រុមប្រឆាំង ច្រើនបាចនៅពេលយប់។ ខិត្តបណ្ណច្រើនមានទំហំប្រហែលសន្លឹកសៀវភៅសរសេរ។

**ខ្ចី**
អ. borrow
បារ. emprunter (v.)

យករបស់របរឬប្រាក់ពីគេមកប្រើប្រាស់ ហើយសងទៅវិញ។

**ខ្សែចង្វាក់តម្លៃ**
អ. value chain

ដំណើរការឬស៊េរីនៃសកម្មភាពដែលត្រូវបានប្រើប្រាស់សម្រាប់បង្កើត និងបន្ថែមតម្លៃទៅលើការផលិត ឬ ការកែច្នៃផលិតផលនៅគ្រប់ដំណាក់កាលនៃខ្សែចង្វាក់ផលិតកម្មទាំងមូល។
ឧ. ដើម្បីមានប្រៀបលើដៃគូប្រកួតប្រជែង ក្រុមហ៊ុនមួយត្រូវសិក្សាឱ្យច្បាស់អំពីខ្សែចង្វាក់តម្លៃនៃផលិតផលរបស់ខ្លួន។

**ខ្សែចង្វាក់ផលិតកម្ម**

អ. production chain

បារ. chaîne de production

ដំណាក់នានាដែលត្រូវការសម្រាប់បំប្លែងវត្ថុធាតុដើមទៅជាផលិតផលពាក់កណ្តាលសម្រេច ឬផលិតផលសម្រេចសម្រាប់អ្នកប្រើប្រាស់។

# គ

**គណនី**
អ. account
បារ. compte ( m. )

បញ្ជី ឬ តារាងកត់ត្រាប្រាក់ចំណូល ចំណាយ និងទ្រព្យ។

ឧ. មន្ត្រីរាជការត្រូវបើកគណនីសម្រាប់កត់ត្រាបៀវត្សរ៍របស់ខ្លួននៅក្នុងធនាគារពាណិជ្ជ ឬ ស្ថាប័នហិរញ្ញវត្ថុណាមួយ។

**គណនេយ្យ**
អ. accounting
បារ. comptabilité ( f. )

ការកត់ត្រាជាប្រព័ន្ធនិងគ្រប់ជ្រុងជ្រោយអំពីប្រតិបត្តិការហិរញ្ញវត្ថុរបស់ក្រុមហ៊ុន អង្គភាព ឬ ស្ថាប័នណាមួយ។

**គណនេយ្យករ**
អ. accountant
បារ. comptable ( n. )

បុគ្គលដែលមានគុណវុឌ្ឍិក្នុងការកត់ត្រានិងការរក្សាបញ្ជីចំណូល ចំណាយ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់សវនកម្មនិងវិភាគគណនី និងការផ្តល់យោបល់លើបញ្ញត្តិពន្ធនានា និងឱកាសវិនិយោគ។

**គណនេយ្យភាព**

អ. accountability

បារ. responsabilité ( f. )

ភាពអាចទទួលខុសត្រូវបាន ភាពអាចគណនាបាន ឬភាពអាចពន្យល់បាន។ ក្នុងន័យទូលាយ «គណនេយ្យភាព»គឺជាទស្សនាទានមួយនៃក្រមសីលធម៌និងអភិបាលកិច្ច ( ethic and governance ) ដែលមានអត្ថន័យទូលំទូលាយ និង អាចត្រូវបានគេប្រើទាំងនៅក្នុងវិស័យសាធារណៈ វិស័យឯកជន និងសង្គមស៊ីវិល។ ក្នុងន័យនេះ«គណនេយ្យភាព» គឺសំដៅទៅលើការទទួលស្គាល់និងការទទួលខុសត្រូវចំពោះសកម្មភាព ការសម្រេចចិត្ត និង គោលនយោបាយ ដែលបានអនុវត្តនៅក្នុងតួនាទីភារកិច្ច និងដែនសមត្ថកិច្ចរបស់ខ្លួន។

**គាំពារនិយម**

អ. protectionism

បារ. protectionnisme ( m. )

សកម្មភាព ឬ គោលនយោបាយរបស់រដ្ឋាភិបាលចំពោះពាណិជ្ជកម្មអន្តរជាតិក្នុងគោលបំណងជួយជ្រោមជ្រែងផលិតផល ឬ សេវាក្នុងស្រុក មានជាអាទិ៍ ការកម្រិតឬការរឹតត្បឹតការនាំចូល ការដាក់ពន្ធទៅលើផលិតផលនាំចូល ការកំណត់កូតា វិធានការរដ្ឋបាល ការឧបត្ថម្ភធន។ល។

ឧ. ប្រទេសកំពុងអភិវឌ្ឍនៅតែជួបប្រទះនឹងបញ្ហាប្រឈមក្នុងការនាំចេញកសិផលទៅប្រទេសអភិវឌ្ឍ

ដែលអនុវត្តគោលនយោបាយគាំពារនិយមតាមរយៈ ការកំណត់អត្រាពន្ធខ្ពស់លើការនាំចូលកសិផល។

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**
អ. microfinance institution
បារ. institution de microfinance

គ្រឹះស្ថានហិរញ្ញវត្ថុឬស្ថាប័នហិរញ្ញវត្ថុឯកជនមានឯកទេសក្នុងការផ្តល់ប្រាក់កម្ចីខ្នាតតូចសម្រាប់ក្រុមឬបុគ្គលមានចំណូលទាប និងសហគ្រាសធុនតូច ហើយមានដើមទុនអប្បបរមាតម្កល់នៅធនាគារជាតិតិចជាងប្រាក់តម្កល់របស់ធនាគារពាណិជ្ជ។

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ**
អ. microfinance deposit taking institution

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលការអនុញ្ញាតពីធនាគារកណ្តាលឱ្យផ្តល់សេវាទទួលប្រាក់បញ្ញើ។

**គ្រឹះស្ថានហិរញ្ញវត្ថុ/ស្ថាប័ន ហិរញ្ញវត្ថុ**
អ. financial institutions
បារ. institution financière /établissement financier

ស្ថាប័នសាធារណៈឬឯកជន ដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ដើម្បីផ្តល់សេវាហិរញ្ញវត្ថុដល់អតិថិជន ដូចជា សេវាប្រាក់កម្ចី សេវាប្រាក់បញ្ញើ សេវាជួញដូរមូលបត្រ សេវាធានារ៉ាប់រង សេវារបបសន្តិសុខសង្គម សេវាវិនិយោគជាដើម។

**គ្រឹះស្ថានឥណទានជនបទ**

អ. rural credit institution

គ្រឹះស្ថានហិរញ្ញវត្ថុមានឯកទេសក្នុងការផ្តល់ប្រាក់កម្ចីខ្នាតតូចនៅជនបទ ហើយមានដើមទុនអប្បបរមាតម្កល់នៅធនាគារជាតិតិចជាងប្រាក់តម្កល់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

# ច

**ចងការ**
អ. borrow/lend (at interest)
បារ. emprunter/prêter (avec intérêt)

ឱ្យខ្ចីប្រាក់ឬខ្ចីប្រាក់ដោយមានការប្រាក់ទៅតាមការព្រមព្រៀងគ្នារវាងអ្នកឱ្យខ្ចីនិងអ្នកខ្ចី។

**ចលនការ**
អ. momentum

និន្នាការកើនឡើង ឬ ថយចុះជាបន្តបន្ទាប់នូវថ្លៃ ឬ បរិមាណនៃមូលបត្រឬទំនិញដែលត្រូវបានជួញដូរក្នុងរយៈពេលមួយ។

ឧ. កំណើនសេដ្ឋកិច្ចកម្ពុជានឹងបន្តមានចលនការក្នុងរង្វង់៧%ចាប់ពីឆ្នាំ២០១៥តទៅ ខណៈពេលដែលកម្ពុជានៅរក្សាបាននូវស្ថិរភាពនយោបាយ និងបន្តអនុវត្តការកែទម្រង់ស៊ីជម្រៅ។

**ចីរភាព**
អ. sustainability
បារ. durabilité (f.)

ភាពបន្តមានជាដរាបនៃដំណើរការអ្វីមួយដោយមិនកំណត់រយៈពេល។ ភាពបន្តមានជាដរាបនេះត្រូវរួមបញ្ចូលទាំងការរក្សាបាននូវបរិស្ថាន ទាំងគុណភាពនៃជីវភាពរស់នៅរបស់មនុស្ស។

ឧ. ដើម្បីធានាកំណើនសេដ្ឋកិច្ចប្រកបដោយ ចីរភាព គោលនយោបាយសេដ្ឋកិច្ចត្រូវផ្សារភ្ជាប់ជាមួយនឹង

ការអភិរក្សបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ។

**ច្រកបែងចែក**
អ. distribution channel
បារ. chaîne de distribution /canal de distribution

ផ្លូវដែលទំនិញនិងសេវាត្រូវបានចែកចាយដោយគិតចាប់ពីក្រោយការផលិតរហូតដល់ការប្រើប្រាស់។

# ជ

**ជវភាព**
អ. dynamics
បារ. dynamique ( f. )

កម្លាំងជំរុញឱ្យមានសន្ទុះនៃកំណើនសេដ្ឋកិច្ចដែលឆ្លុះបញ្ចាំងពីការប្រែប្រួលឥរិយាបថទីផ្សារ សកម្មភាពធុរកិច្ច ការងារ ផលិតកម្ម ការវិនិយោគជាដើម។

**ជវភាពប្រជាសាស្ត្រ**
អ. demographic dynamics
បារ. dynamique démographique

ស្ថានភាពប្រជាសាស្ត្រដែលនាំឱ្យ ឬ ធ្វើឱ្យសកម្មភាពសង្គម-សេដ្ឋកិច្ចមានការវិវឌ្ឍ។

# ដ

**ដៃអរូប**

អ. invisible hand

គោលការណ៍សេដ្ឋកិច្ចទីផ្សារដែលដំណើរការដោយតួអង្គ ឬ ភ្នាក់ងារជាច្រើនរួមមាន អ្នកទិញ អ្នកលក់ អ្នកផលិត។ល។ ដោយសេរីនៅក្នុងទីផ្សារប្រកួតប្រជែង ដោយផ្អែកលើអត្ថប្រយោជន៍ផ្ទាល់ខ្លួន និងពុំមានអន្តរាគមន៍របស់រដ្ឋ។

ឧ. ក្រោយពីពិភពលោកជួបប្រទះនូវវិសម្ភាធសេដ្ឋកិច្ចធ្ងន់ធ្ងរនាទសវត្សរ៍ទី៣នៃសតវត្សរ៍ទី២០ ប្រទេសនានាលើពិភពលោកបានឈប់ប្រកាន់យកសេដ្ឋកិច្ចបែបដៃអរូប ដោយរដ្ឋចាប់ផ្ដើមអន្តរាគមន៍ក្នុងសេដ្ឋកិច្ច តាមរយៈការដាក់ចេញនូវគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងបទបញ្ញត្តិនានា។

# ឋ

**ឋានានុក្រមកម្ម/ឋានានុក្រមនីយកម្ម** ការបែងចែកឬការរៀបចំតាមឋានានុក្រម។ ការបែងចែកឬការរៀបចំជាឋានានុក្រម។

អ. hierarchization

បារ. hiérarchisation ( f. )

# ត

**តម្លាភាព**

អ. transparency

បារ. transparence (f.)

បរិយាកាសនៃការបើកទូលាយដល់ការចូលរួម ការតាមដាន ការពិនិត្យ និងការផ្ដល់យោបល់គ្រប់ជ្រុងជ្រោយក៏ដូចការប្រកួតប្រជែងដោយសមធម៌ ដោយលក្ខណៈស្មើភាពនិងយុត្តិធម៌។ បរិយាកាសនៃការប្រកួតប្រជែងដែលមានលក្ខណៈស្មើភាពនិងយុត្តិធម៌ អនុញ្ញាតឱ្យតួអង្គទាំងអស់មានឱកាសដូចគ្នាដើម្បីការចូលរួម ប្រសិនបើគេមានបំណងចូលរួម។

ឧ. តម្លាភាពនៃការអនុវត្តថវិកាឃុំ សង្កាត់ អនុញ្ញាតឱ្យប្រជាពលរដ្ឋអាចចូលរួមតាមដានត្រួតពិនិត្យអំពីដំណើរការគម្រោងអភិវឌ្ឍន៍នៅតាមមូលដ្ឋានរបស់ខ្លួន។

**តំណាងផ្នែកលក់**

អ. sale representative

បារ. représentant des ventes/représentant commercial

អ្នកទាក់ទងអតិថិជន ដែលមានសមត្ថភាពយល់នូវអ្វីដែលអ្នកទិញចង់បានពន្យល់នីតិវិធីនៃការទិញ និងធានាដល់ដំណើរការលក់ឱ្យបានរលូន។

**តំបន់សេដ្ឋកិច្ចពិសេស**

អ. special economic zone

បារ. zone économique spéciale

តំបន់ដែលគ្រប់គ្រងដោយច្បាប់ និង បទបញ្ញត្តិដោយឡែកពីតំបន់ដទៃទៀត នៅក្នុងប្រទេសតែមួយ ជាពិសេស ដើម្បីទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស។

ជាទូទៅ ក្រុមហ៊ុនដែលវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ទទួលបានការលើកទឹកចិត្តផ្សេងៗដូចជាការលើកទឹកចិត្តផ្នែកពន្ធដារ និងពន្ធគយ។

# ថ

**ថ្លៃ**
អ. price
បារ. prix ( m. )

ចំនួនប្រាក់នៃតម្លៃទំនិញឬសេវាចេញមកពីការដោះដូរ។

**ថ្លៃកម្រិត**
អ. fixed price
បារ. prix fixe

ថ្លៃទំនិញឬសេវាដែលមិនអាចតថ្លៃបាន។

**ថ្លៃដើម**
អ. cost
បារ. coût ( m. )/prix de revient

ចំនួនប្រាក់ចំណាយដើម្បីផលិតជាទំនិញឬសេវា ដូចជាចំណាយទៅលើវត្ថុធាតុដើម មូលធន កម្លាំងពលកម្ម និងសហគ្រិនភាព។

**ថ្លៃផ្សារ**
អ. market price
បារ. prix ( m. ) de marché

ថ្លៃទិញឬលក់ជាទូទៅនៃទំនិញឬសេវានៅផ្សារ។

**ថ្លៃបាត**
អ. price floor

ថ្លៃអប្បបរមាដែលដាក់ចេញដោយស្ថាប័នសាធារណៈទៅលើការកំណត់ថ្លៃលក់ទំនិញ ឬ សេវានៅក្នុងទីផ្សារ។

ឧ. រាជរដ្ឋាភិបាលកម្ពុជាធ្លាប់បានកំណត់ថ្លៃបាត

ចំពោះសេវាទូរគមនាគមន៍ ដើម្បីការពារការលក់បង្ហូចថ្លៃ។

**ថ្លៃពិតាន**

អ. price ceiling

ថ្លៃអតិបរមាដែលដាក់ចេញដោយស្ថាប័នសាធារណៈទៅលើការកំណត់ថ្លៃលក់ទំនិញ ឬសេវានៅក្នុងទីផ្សារ។

ឧ. ពេលមានទឹកជំនន់ រដ្ឋបានកំណត់ថ្លៃពិតានទៅលើថ្លៃលក់អង្ករ ដើម្បីចៀសវាងការធ្វើវិច្ឆេទកម្មក្នុងទីផ្សារ។

**ថ្លៃលក់**

អ. selling price

បារ. prix de vente

ថ្លៃទំនិញឬសេវាដែលដាក់លក់នៅលើទីផ្សារ។

**ថ្លៃលក់ផ្តាច់**

អ. sale price

បារ. prix soldé

ថ្លៃទំនិញឬសេវាដែលលក់ដោយមានការបញ្ចុះថ្លៃរួច។

**ទស្សន៍លទ្ធភាព**
អ. predictability
បារ. prévisibilité (f.)/
prédictibilité (f.)

ភាពអាចប៉ាន់ប្រមាណទុកជាមុននូវស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ទាយជ្ជទាន**
អ. endowment
បារ. dotation (f.)

ន័យហិរញ្ញវត្ថុ : មូលនិធិ ឬ ទ្រព្យសម្បត្តិដែលផ្តល់ជាទុនទៅស្ថាប័ន បុគ្គល ឬ ក្រុម សម្រាប់គោលដៅជាក់លាក់អ្វីមួយ។
ឧ. រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ទាយជ្ជទានទៅធនាគារអភិវឌ្ឍន៍ជនបទដើម្បីជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករទៅក្រៅប្រទេស។
ន័យសេដ្ឋកិច្ច : ធនធាន ឬ កត្តាផលិតកម្មដែលប្រទេសមួយមានសម្រាប់ប្រើប្រាស់ ឬ ផលិតទំនិញនិងសេវាកម្ម។
ឧ. ធនធានធម្មជាតិគឺជាទាយជ្ជទានរបស់កម្ពុជាដែលចូលរួមទាក់ទាញវិនិយោគិនក្នុងនិងក្រៅស្រុកឱ្យមកវិនិយោគនៅក្នុងប្រទេស។

**ទុនចុះបញ្ជី**
អ. registered capital / authorized capital
បារ. capital enregistré

ទុនផ្លូវការដែលក្រុមហ៊ុនមាននៅពេលចុះបញ្ជីពាណិជ្ជកម្ម។

**ទ្រព្យ**
អ. wealth
បារ. richesse ( f. )

តម្លៃទ្រព្យសកម្មដែលមានក្រោយពីដកចេញនូវបំណុលដែលជំពាក់គេ។

**ទ្រព្យសកម្ម**
អ. assets
បារ. actifs ( m. pl. )

ប្រាក់និងអ្វីៗផ្សេងទៀតដែលជាកម្មសិទ្ធិរបស់រូបវន្តបុគ្គលឬនីតិបុគ្គល ហើយដែលអាចទូទាត់បំណុល ប្រើប្រាស់ ទទួលអត្ថប្រយោជន៍ និងបង្កើនប្រាក់ចំណូលបាន។

**ទ្រព្យសកម្មចរន្ត**
អ. current assets
បារ. actifs à court terme / actifs courants

ទ្រព្យសកម្មដែលអាចបំប្លែងជាប្រាក់បានក្នុងរយៈពេលមួយខួបផលិតកម្មឬក្នុងរយៈពេលមិនលើសពីមួយឆ្នាំ។

**ទ្រព្យសកម្មរូបី**
អ. tangible assets
បារ. actifs corporels/ actif tangible

ទ្រព្យសកម្មដែលមានរូប រួមមានទ្រព្យសកម្មចរន្ត និងទ្រព្យសកម្មអចល័ត។

**ទ្រព្យសកម្មអចល័ត**

អ. fixed assets

បារ. immobilisations/ actifs immobilisés

ទ្រព្យសកម្មដែលអាចបំប្លែងជាប្រាក់បានក្នុងរយៈពេលច្រើនខួបផលិតកម្មឬក្នុងរយៈពេលលើសពីមួយឆ្នាំ។

**ទ្រព្យសកម្មអរូបី**

អ. intangible assets

បារ. actif incorporel/actif intangible

ទ្រព្យសកម្មដែលមិនមានរូប ដូចជាកម្មសិទ្ធិបញ្ញា ប្រកាសនីយបត្រតក្កកម្ម ពាណិជ្ជសញ្ញា សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល វិធីសាស្ត្រធុរកិច្ចជាដើម។

# ធ

**ធនាគារ**

អ. bank

បារ. banque (f.)

គ្រឹះស្ថានហិរញ្ញវត្ថុដែលមាននីតិសម្បទាពិសេសក្នុងការរើសយកប្រតិបត្តិការដូចខាងក្រោមនេះជាមុខរបរ៖

- ការផ្តល់ឥណទានគ្រប់ប្រភេទចំពោះសាធារណជនដោយមានកម្រៃ រាប់បញ្ចូលទាំងឥណទានភតិសន្យានិងការសន្យាតាមហត្ថលេខា
- ការទទួលប្រាក់បញ្ញើមិនមានមុខសញ្ញាប្រើពីសាធារណជន
- ប្រព្រឹត្តិកម្មនិងការដាក់ឱ្យអតិថិជនប្រើប្រាស់នូវមធ្យោបាយទូទាត់ជារូបិយវត្ថុឬជារូបិយបណ្ណ។

**ធនាគារកណ្តាល**

អ. central bank

បារ. banque centrale

ធនាគារសាធារណៈដែលមានសមត្ថកិច្ចផ្តាច់មុខលើ៖

- ការកំណត់គោលនយោបាយរូបិយវត្ថុនិងការគ្រប់គ្រងចំនួនឥណទានសរុប
- ការគ្រប់គ្រងនិងការត្រួតពិនិត្យគ្រឹះស្ថានហិរញ្ញវត្ថុតាមរយៈការចេញប្រកាសបទបញ្ជានិងសេចក្តីណែនាំផ្សេងៗ។

**ធនាគារពាណិជ្ជ**
អ. commercial bank
បារ. banque commerciale

ធនាគារឯកជនដែលទទួលបានអាជ្ញាបណ្ណពីធនាគារកណ្តាល ដើម្បីធ្វើប្រតិបត្តិការស្វែងរកប្រាក់ចំណេញ។

**ធនាគារឯកទេស**
អ. specialized bank
បារ. banque spécialisée

ធនាគារដែលអនុវត្តតែប្រតិបត្តិការមួយតាមជំនាញជាក់លាក់ក្នុងចំណោមប្រតិបត្តិការទាំងបីរបស់ធនាគារ។

# ន

**នាយកផ្នែកលក់**
អ. sale director
បារ. directeur de vente

អ្នកគ្រប់គ្រងម្នាក់ក្នុងចំណោមអ្នកគ្រប់គ្រងទាំងឡាយដែលទទួលបន្ទុករៀបចំយុទ្ធសាស្ត្រលក់ និងទទួលខុសត្រូវចំពោះដំណើរការលក់ក្នុងអង្គភាពអាជីវកម្ម។

**និកម្មភាព**
អ. unemployment
បារ. chômage ( m. )

ភាពគ្មានការងារធ្វើកើតឡើងក្នុងស្ថានភាពដែលមនុស្សម្នាក់ដល់អាយុធ្វើការ មានសមត្ថភាព និងមានបំណងធ្វើការ បានខិតខំស្វែងរកការងារធ្វើ ប៉ុន្តែពុំអាចរកការងារបាន។
ឩ. បច្ចុប្បន្ននេះ និកម្មភាពនៅកម្ពុជាបានថយចុះគួរឱ្យកត់សម្គាល់ ខណៈពេលដែលមានក្រុមហ៊ុនវិនិយោគបានបង្កើតការងារជាច្រើន។

**និមិត្តសញ្ញា**
អ. logo
បារ. logo ( m. )

រូបរចនាក្បាច់ក្បូរ( មានឬគ្មានអក្សរ )សម្រាប់ជានិមិត្តរូបនៃស្ថាប័ន អង្គការ ឬ ក្រុមហ៊ុនណាមួយ។

**និរន្តរភាព**
អ. continuity
បារ. continuité ( f. )

ភាពដែលអាចកើតមានជាបន្តបន្ទាប់ឥតដាច់ ឬលទ្ធភាពនៃការប្រើប្រាស់ជាបន្តបន្ទាប់ឥតដាច់នៃធនធានសេដ្ឋកិច្ចឬហិរញ្ញវត្ថុ ដោយពុំគិតបញ្ចូលការរក្សាបាន ឬ ការពង្រីកបាននូវគុណភាព និង

វឌ្ឍនភាព។

ឧ.  ការបង្ហូរកាកសំណល់ពីរោងចក្រចូលទៅក្នុងស្ទឹងធ្វើឱ្យបាត់និរន្តរភាពសម្រាប់ការប្រើប្រាស់ទឹក និងរបរនេសាទ។

**នីតិសម្បទា**

អ. rehabilitation

បារ. réhabilitation ( f. )

ការស្ដារ ការកសាង ឬការកែលម្អឱ្យមានភាពប្រក្រតីឡើងវិញនូវក្រុមហ៊ុន ស្ថាប័ន ឬ ហេដ្ឋារចនាសម្ព័ន្ធសង្គម សេដ្ឋកិច្ច ដែលខ្ទេចខ្ទាំខូចខាត។

ឧ. ជំនួយអភិវឌ្ឍន៍នានាបានរួមចំណែកយ៉ាងសំខាន់ក្នុងការស្ដារនីតិសម្បទាសេដ្ឋកិច្ចកម្ពុជាឡើងវិញ។

# ប

**បញ្ចាំ** ដាក់ទ្រព្យជាថ្នូរសម្រាប់ធានាយកប្រាក់កម្ចី។

អ. pawn

បារ. mettre en gage

**បដា** ផ្ទាំងសំពត់ដែលគេសរសេរអក្សរជាពាក្យសុភាសិត ពាក្យស្លោក ឬ ពាក្យអ្វីផ្សេងៗសម្រាប់កាន់ហែជាក្បួន ឬ ចងសន្ធឹងទទឹងផ្លូវ : ធ្វើបដា កាន់បដា យកបដា ទៅចងសន្ធឹងលើផ្លូវ។ (វចនានុក្រមសម្ដេច ជួន ណាត)។

អ. banderol, streamer

បារ. banderole ( f. )

**បដិផរណា** ការធ្លាក់ចុះនៃអត្រាអតិផរណា។

អ. disinflation

បារ. désinflation ( f. )

**បណ្ណធនាគារ** ឧបករណ៍ទូទាត់មួយប្រភេទ ដែលធនាគារពាណិជ្ជចេញឱ្យអតិថិជន ដើម្បីឱ្យអ្នកកាន់បណ្ណនោះអាចដកប្រាក់ក្នុងចំនួនជាក់លាក់មួយពីគណនីរបស់ធនាគារនោះ ដែលមាននៅធនាគារអន្តរការី ឬធនាគារផ្សេងនៅឯក្រៅប្រទេស។ ជាទូទៅបណ្ណធនាគារត្រូវបានគេប្រើជាឧបករណ៍សុវត្ថិភាពមួយដើម្បីទូទាត់ប្រាក់នៅក្រៅប្រទេស។

អ. bank draft

បារ. traite bancaire/lettre de change bancaire

**បណ្ណបង់ប្រាក់មុន/កាតបង់ប្រាក់មុន**

អ. prepaid card

បារ. carte prépayée

បណ្ណមួយប្រភេទដែលគេប្រើសម្រាប់ទូទាត់ថ្លៃទំនិញ ឬសេវាជាក់លាក់ជំនួសការទូទាត់ជាប្រាក់ ក្រោយពីគេបញ្ចូលប្រាក់ជាមុនក្នុងគណនី។

**បណ្ណប្រកាស**

អ. leaflet

បារ. dépliant (m.)/ prospectus (m.)

បរិយាយបណ្ណជាក្រដាសឬសន្លឹកធ្វើអំពីវត្ថុធាតុផ្សេងៗដែលបានបោះពុម្ព និងរចនាឡើងមួយ ឬច្រើនទំព័របត់ជាពីរបីផ្នត់ (ជាពិសេសdépliant) សម្រាប់ចែកជូនដោយមិនគិតថ្លៃដើម្បីផ្តល់ព័ត៌មានអំពីអ្វីមួយ។

**បណ្ណឥណទាន**

អ. credit card

បារ. carte de crédit

បណ្ណប្រើសម្រាប់ទូទាត់ថ្លៃទំនិញឬសេវាតាមចំនួនប្រាក់ដែលធនាគារបានកំណត់ ហើយទូទាត់ឱ្យទៅធនាគារវិញនៅពេលក្រោយ។

**បណ្ណឥណពន្ធ**

អ. debit card

បារ. carte de débit

បណ្ណប្រើសម្រាប់ទូទាត់ថ្លៃទំនិញឬសេវាតាមចំនួនប្រាក់ដែលមាននៅក្នុងគណនីរបស់ម្ចាស់បណ្ណ។

**បណ្ណអេធីអឹម/កាតអេធីអឹម**

អ. ATM card

បារ. carte GAB

បណ្ណដែលអតិថិជនប្រើជាមួយម៉ាស៊ីនអេធីអឹម/ម៉ាស៊ីនប្រតិបត្តិការធនាគារស្វ័យប្រវត្តសម្រាប់ធ្វើប្រតិបត្តិការជាមួយធនាគារតាមប្រព័ន្ធអេឡិចត្រូនិក។

**បណ្តាក់**

ផ្តល់ប្រាក់ឬទំនិញនិងទទួលប្រាក់ឬទំនិញ ដែលក្រោយមកអ្នកទទួលប្រាក់ឬទំនិញនោះត្រូវសងតាមចំនួននិងពេលកំណត់តាមការព្រមព្រៀង។

**បរិការណ៍**

អ. context

បារ. contexte ( m. )

ការណ៍ទាំងឡាយដែលកើតមុននិងក្រោយព្រឹត្តិការណ៍មួយ។

ពាក្យនេះប្រើខុសពីបរិបទដែលសំដៅដល់ខ្លឹមសារណាមួយដែលត្រូវលើកឡើងនូវពីមុខឬពីក្រោយសេចក្តីមួយ។

ក្នុងន័យសេដ្ឋកិច្ច«បរិការណ៍»ប្រើសំដៅបង្ហាញការណ៍ណាមួយដែលកើតឡើងនៅជុំវិញព្រឹត្តិការណ៍មួយ។

ឧ. ក្នុងស្មារតីនេះ កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៤នៃរដ្ឋសភាត្រូវបានរៀបចំឡើងនៅលើមូលដ្ឋានសំខាន់ៗដូចតទៅៈ

ការវាយតម្លៃដកពិសោធន៍លើការអនុវត្តនៅក្នុងនីតិកាលទី៣កន្លងមក និង ការវាយតម្លៃលើបរិការណ៍ និង បញ្ហាប្រឈមទាំងឡាយទាំងក្នុងកម្រិតជាតិ ទាំងក្នុងកម្រិតអន្តរជាតិ ទាំងក្នុងពេល

បច្ចុប្បន្ន ទាំងក្នុងរយៈពេលមធ្យម(ខាងមុខ)។ ដោយឡែក«បរិបទ»ប្រើយោងទៅតាមសេចក្តីណាមួយ។

២. តាមរយៈរបៀបវារៈនៃអង្គសន្និសីទក្រសួងឧស្សាហកម្មរ៉ែនិងថាមពលនឹងធ្វើបទបង្ហាញអំពីបរិបទ និងស្ថានភាពវិស័យរ៉ែនៅកម្ពុជាជូនអង្គសន្និសីទទាំងមូលឱ្យកាន់តែជ្រាបច្បាស់ថែមទៀតអំពីច្បាប់ លិខិតបទដ្ឋាន និងស្ថានភាពនៃការគ្រប់គ្រងនិងការអភិវឌ្ឍរ៉ែនៅកម្ពុជា។

**បរិយាបន្នកម្ម**

អ. inclusiveness

បារ. inclusion (f.)

វិធានការ ឬ គោលនយោបាយដែលរាប់បញ្ចូល ឬ ផ្តល់លទ្ធភាពដល់អ្នកពាក់ព័ន្ធទាំងអស់ដើម្បីទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចពីដំណើរការនៃការអនុវត្ត គម្រោងកម្មវិធី ឬ គោលនយោបាយ។

២. ការបង្កលក្ខណៈឱ្យជនពិការមានការងារធ្វើជាបរិយាបន្នកម្មនៃដំណើរការអភិវឌ្ឍសង្គម សេដ្ឋកិច្ច។

**បរិយាបន្នកម្មហិរញ្ញវត្ថុ**

អ. financial inclusiveness

បារ. inclusion financière

សេវាកម្មហិរញ្ញវត្ថុដែលត្រូវបានគេគិតគូរដល់ក្រុមភាគតិច និងក្រុមងាយរងគ្រោះ បានទទួលចំណែកផល ឬជាវិធានការ ឬគោលនយោបាយ ដែលរាប់បញ្ចូល ឬ ផ្តល់លទ្ធភាពដល់អ្នកពាក់ព័ន្ធទាំងអស់ដើម្បីទទួលបានអត្ថប្រយោជន៍ហិរញ្ញវត្ថុពីដំណើរការនៃការអនុវត្តគម្រោង កម្មវិធី ឬ គោលនយោបាយ។

ឧ. ការពង្រីកវិសាលភាពនៃសេវាមីក្រូហិរញ្ញវត្ថុដល់ជនបទ ជាបរិយាបន្នកម្មហិរញ្ញវត្ថុ មានលក្ខណៈកាន់តែទូលំទូលាយ។

**បរិយាសកាសវិនិយោគ**

អ. investment climate

លក្ខខណ្ឌទាំងឡាយដែលមានឥទ្ធិពលលើការសម្រេចចិត្តរបស់វិនិយោគិន។ លក្ខខណ្ឌទាំងនោះមានដូចជា សន្តិភាព សន្តិសុខ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ឧក្រិដ្ឋកម្ម អស្ថិរភាពនយោបាយ ភាពក្រីក្រ កម្លាំងពលកម្ម ហេដ្ឋារចនាសម្ព័ន្ធ គាំទ្រប្រព័ន្ធយុត្តិធម៌ ច្បាប់ បទបញ្ញត្តិជាដើម។

ឧ. ការរក្សាបាននូវសន្តិភាព ស្ថិរភាពនយោបាយ និងសេដ្ឋកិច្ច និងការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធផ្លូវ ស្ពាន និង ប្រព័ន្ធច្បាប់ បានធ្វើឱ្យបរិយាកាសវិនិយោគនៅកម្ពុជាកាន់តែមានភាពល្អប្រសើរឡើងក្នុងការទាក់ទាញវិនិយោគពីបរទេស។

**បរិស្ថានអនុគ្រោះ**
អ. favorable environment

លក្ខណៈ ឬ លក្ខខណ្ឌអំណោយផលសម្រាប់ដំណើរការធុរកិច្ច។
ឧ. ស្ថិរភាពនយោបាយនិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចជាបរិស្ថានអនុគ្រោះសម្រាប់ការប្រកបអាជីវកម្មនៅកម្ពុជា។

**ប៉ង់កាត**
អ. placard
បារ. pancarte (m.)

ផ្លាកធ្វើពីឈើឬក្រដាសក្រាស់។ល។ ដែលនៅលើនោះមានសរសេរអក្សរសម្រាប់លើកបង្ហាញព័ត៌មានទាក់ទងនឹងអ្វីមួយ។

**ប៉ាណូ**
អ. billboard/hoarding
បារ. panneau (m.)

ផ្ទាំងរាបស្មើ( ធ្វើពីឈើ លោហៈ ...) ដែលគេប្រើសម្រាប់ចារឬសរសេរពីលើ។
គេច្រើនភ្ជាប់ឬព្យួរប៉ាណូនឹងជញ្ជាំងអគារដែលមានមនុស្សចេញចូលច្រើនឱ្យគេដឹងអំពីអ្វីមួយ។

**ប៉ូលកំណើនសេដ្ឋកិច្ច**
អ. economic growth pole

ទីកន្លែងប្រមូលផ្តុំសកម្មភាពសេដ្ឋកិច្ច ពាណិជ្ជកម្មសម្រាប់ជំរុញកំណើនសេដ្ឋកិច្ច។
ឧ. កម្ពុជាមានប៉ូលកំណើនសេដ្ឋកិច្ច៤កន្លែងគឺរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តព្រះសីហនុ និងភូមិភាគឦសាន។

**បុព្វលក្ខខណ្ឌ**

អ. precondition

បារ. condition préalable

លក្ខខណ្ឌចាំបាច់ដែលត្រូវមានជាមុន សម្រាប់ធានាដល់ដំណើរការចាប់ផ្ដើមការកើនឡើង និងការរីកលូតលាស់នៃសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ បុព្វលក្ខខណ្ឌនេះ មានសន្តិភាព ស្ថិរភាពនយោបាយ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ស្ថិរភាពសង្គម។ល។

ឧ. សន្តិភាពនិងស្ថិរភាពនយោបាយ ជាបុព្វលក្ខខណ្ឌសម្រាប់ជំរុញកំណើនសេដ្ឋកិច្ច។

**បុរេសកម្ម**

អ. proactive

ដែលធ្វើសកម្មភាពជាមុនឬការត្រៀមជាមុន ដើម្បីបង្ការ បម្រុង ការពារ បញ្ជៀស ឬ ទប់ទល់នឹងផលវិបាកអវិជ្ជមាននៃវិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬ ដើម្បីទាញយកអត្ថប្រយោជន៍ពីដំណើរវិវត្តនៃសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ឧ. ការដាក់ចេញនូវ "គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥" ជាសកម្មភាពដែលមានលក្ខណៈបុរេសកម្ម ដើម្បីរួមចំណែកដល់ការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និងបរិយាបន្ន ខណៈពេលដែលសេដ្ឋកិច្ចនៅអាស៊ីកំពុងលូតលាស់ ជាពិសេសនៅពេលដែលសហគមន៍សេដ្ឋកិច្ចអាស៊ាននឹងត្រូវចាប់ផ្ដើមពីឆ្នាំ២០១៦។

**បុល**
បារ. prêter/emprunter à usure

ផ្តល់ប្រាក់ឬផ្តល់ទំនិញនិងទទួលប្រាក់ឬទំនិញក្រៅប្រព័ន្ធ ដែលក្រោយមកកូនបំណុលនោះត្រូវសងប្រាក់ឬទំនិញនោះមួយជាពីរតាមពេលកំណត់ និង តាមការព្រមព្រៀង។

**បេឡាធិការ**
អ. cashier
បារ. caissier ( m. )

អ្នកទទួលខុសត្រូវប្រតិបត្តិការទទួលប្រាក់និងបញ្ចេញប្រាក់នៅក្នុងស្ថាប័នរដ្ឋ ក្រុមហ៊ុនឯកជនជាដើម។

**បំណុល**
អ. debt
បារ. dette ( f. )

ប្រាក់ ទំនិញ សេវា ឬកាតព្វកិច្ចសរុបដែលអ្នកជំពាក់ត្រូវសងតាមលក្ខខណ្ឌនៃកិច្ចសន្យា។

**បំណុលសាធារណៈ**
អ. public debt
បារ. dette publique

បំណុលជាកាតព្វកិច្ចដែលរដ្ឋាភិបាលរបស់ប្រទេសមួយត្រូវទូទាត់សងទៅតាមលក្ខខណ្ឌនិងកាលបរិច្ឆេទជាក់លាក់។ បំណុលសាធារណៈកើតឡើងដោយសារឱនភាព ថវិការបស់រដ្ឋាភិបាល។

**ប្រតិបត្តិករផ្នែកលក់**
អ. sale executive
បារ. responsable de vente / cadre commercial/ cadre de vente

បុគ្គលិកគន្លឹះសម្រាប់ការទាក់ទងរវាងអង្គភាពអាជីវកម្មនិងអតិថិជនដើម្បីឆ្លើយតបសំណួរនិងសំណូមពរ បង្ហាញផលិតផលថ្មីៗ តាំងពិព័រណ៍និងផ្តួចផ្តើមគំនិតថ្មីក្នុងការលក់ផលិតផល។

**ប្រធានក្រុមផ្នែកលក់**
អ. sale team leader
បារ. chef d'équipe de vente

អ្នកដឹកនាំក្រុមអ្នកលក់ ដែលទទួលភារកិច្ចផ្ទាល់ពីប្រធានផ្នែកលក់ ដើម្បីធ្វើឱ្យសម្រេចបានគោលដៅការលក់ប្រចាំថ្ងៃនិងទទួលបានការពេញចិត្តពីអតិថិជន។

**ប្រធានផ្នែកលក់**
អ. head of sales
បារ. chef de vente

អ្នកទទួលខុសត្រូវផ្នែកមួយនៃការលក់ ហើយស្ថិតនៅក្រោមអ្នកគ្រប់គ្រងផ្នែកលក់។

**ប្រភេទវិទ្យា**
អ. typology
បារ. typologie (f.)

វិទ្យាសាស្ត្រនៃការបែងចែកទៅតាមប្រភេទទូទៅ ដើម្បីសម្រួលដល់ការធ្វើវិភាគនៃតថភាពស្មុគស្មាញ។

**ប្រវាស់**

ចូលហ៊ុនរកស៊ី ដោយភាគីម្ខាងមានរបស់ទ្រព្យ ភាគីម្ខាងទៀតមានកម្លាំងពលកម្មនិងមធ្យោបាយផ្សេងៗ ទទួលអនុវត្តការងារ ហើយបែងចែកផលប្រយោជន៍តាមការព្រមព្រៀង។

**ប្រសិទ្ធភាព**
អ. effectiveness
បារ. efficacité (f.)

កម្រិត ឬ សមត្ថភាពដែលសម្រេចបានជាលទ្ធផលតាមការគ្រោងទុក ឬ តាមគោលបំណងនៃការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។

ឧ. រដ្ឋាភិបាលកម្ពុជាអនុវត្តថវិកាដោយភាពប្រុងប្រយ័ត្នតាមរយៈការបង្កើនប្រសិទ្ធភាពនៃចំណាយ

ចរន្ត ដើម្បីរក្សាឱនភាពឱ្យស្ថិតនៅក្នុងកម្រិតដែលអាចធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចបាន។

**ប្រាក់**
អ. cash
បារ. monnaie ( f. )

រូបិយវត្ថុមានទម្រង់រូបវន្តជាក្រដាសនិងកាស។

**ប្រាតិភោគ**
អ. collateral
បារ. collatéral ( m. )

ទ្រព្យសម្បត្តិឬវត្ថុមានតម្លៃដែលអ្នកខ្ចីប្រាក់ដាក់តម្កល់ជាការធានា។

ឧ. អតិថិជនដែលខ្ចីប្រាក់ពីធនាគារពាណិជ្ជនៅកម្ពុជាត្រូវដាក់តម្កល់អចលនវត្ថុធ្វើជាប្រាតិភោគ។

# ផ

**ផលិតផល**
អ. product
បារ. produit ( m. )

ទំនិញឬសេវាដែលបានបង្កើតឡើងដើម្បីបំពេញតម្រូវការអតិថិជនដោយអាចរួមបញ្ចូលទាំងព័ត៌មានអំពីធាតុផ្សំ អត្ថប្រយោជន៍ លក្ខណៈពិសេស របៀបប្រើប្រាស់។ល។

**ផលិតផលក្នុងស្រុកសរុប (ផ.ស.ស.)**
អ. gross domestic product ( GDP )
បារ. produit intérieur brut ( PIB )

តម្លៃសរុបនៃទំនិញនិងសេវាដែលបានផលិតដោយប្រជាជនក្នុងប្រទេសណាមួយក្នុងរយៈពេលមួយឆ្នាំដោយមិនរាប់បញ្ចូលតម្លៃនៃប្រាក់ចំណូលបានពីបរទេសទេ។

**ផលិតផលជាតិសរុប (ផ.ជ.ស.)**
អ. gross national product ( GNP )
បារ. produit national brut ( PNB )

តម្លៃសរុបនៃទំនិញនិងសេវាដែលបានផលិតដោយប្រជាជននៃប្រទេសណាមួយក្នុងរយៈពេលមួយឆ្នាំ។

**ផែនការអាជីវកម្ម/ផែនការធុរកិច្ច**
អ. business plan
បារ. projet commercial

ឯកសារជាលាយលក្ខណ៍អក្សរពិពណ៌នាអំពីជំហានចាំបាច់ទាំងអស់ ដើម្បីចាប់ផ្ដើមនិងប្រតិបត្តិការអាជីវកម្មឱ្យបានជោគជ័យ។ ចំណុចសំខាន់ៗនៃផែនការអាជីវកម្មមានដូចជា គោលបំណង គោលដៅ សកម្មភាព ធនធានមនុស្ស ថវិកាដែលត្រូវចំណាយជាដើម។

**ផ្ទាំង**

បន្ទះធំ ស្រទាប់ធំ ផ្ទៃ : ជញ្ជាំងមួយផ្ទាំង។ (វចនានុក្រមសម្ដេច ជួន ណាត)។

**ផ្លាក**
បារ. plaque (f.)

សន្លឹកធ្វើអំពីលោហៈ ឈើ ឬ របស់ផ្សេងៗទៀតដែលមានលក្ខណៈរឹង សំប៉ែត ស្ដើង តូចជាងផ្ទាំង និង មានរាងផ្សេងៗ ប៉ុន្តែជាទូទៅច្រើនមានរាងចតុកោណសម្រាប់ប្រើកត់ត្រាសម្គាល់លេខរថយន្ត ទោចក្រយានយន្ត ត្រីចក្រយានយន្ត គេហដ្ឋាន តួនាទី កន្លែងធ្វើការ។ល។

**ផ្លាកពាណិជ្ជកម្ម**
អ. publicity hoarding
បារ. panneau-réclame

ផ្លាកដែលគេដាក់ផ្សព្វផ្សាយពាណិជ្ជកម្មនៅតាមទីសាធារណៈ នៅតាមថ្នល់ដែលមានចរាចរណ៍ច្រើនជាដើម ដូចជា ផ្លាកពាណិជ្ជកម្មទឹកបរិសុទ្ធវីតាល់ ស្រាបៀរអង្គរជាដើម។

**ផ្លាកយីហោ**
អ. signboard
បារ. enseigne ( f. )

ផ្លាកដែលដាក់នៅលើទ្វារចូលទៅហាងទំនិញ ភោជនីយដ្ឋានជាដើម។

**ផ្សារកត្តាផលិតកម្ម**
អ. production factor market

ផ្សារដែលទិញឬលក់កម្លាំងពលកម្ម មូលធនផលិតផលកែច្នៃរួច វត្ថុធាតុដើម និង សហគ្រិនភាព។
ឧ. ផ្សារកត្តាផលិតកម្មរបស់កម្ពុជាសំខាន់ៗពឹងផ្អែកលើធនធានធម្មជាតិ និង កម្លាំងពលកម្ម។

**ផ្សារផលិតផល**
អ. product market

ផ្សារដែលផលិតផលសម្រេចឬសេវាត្រូវបានទិញនិងលក់។
ឧ. សហរដ្ឋអាមេរិកជាផ្សារផលិតផលវាយនភណ្ឌរបស់កម្ពុជា។

**ផ្សាររូបិយបណ្ណ**
អ. currency market
បារ. marché de devises

ផ្សារអន្តរជាតិសម្រាប់ដោះដូររូបិយបណ្ណផ្សេងៗ និងជួយកំណត់តម្លៃរបស់រូបិយវត្ថុមួយធៀបនឹងរូបិយវត្ថុមួយទៀត។
ឧ. ប្រាក់ដុល្លារអាមេរិកជារូបិយវត្ថុអន្តរជាតិដែលមានការជួញដូរច្រើនបំផុតនៅក្នុងផ្សាររូបិយបណ្ណ។

# ព

**ពន្ធ**
អ. tax
បារ. impôt (m.)

ប្រាក់ដែលនីតិបុគ្គលឬរូបវន្តបុគ្គលជាប់កាតព្វកិច្ចត្រូវបង់ជូនរដ្ឋតាមការកំណត់ សម្រាប់ចំណាយសាធារណៈ។

**ពន្ធគយ**
អ. custom duty
បារ. droits de douane

ពន្ធយកលើទំនិញនាំចេញ នាំចូល ឬឆ្លងកាត់ប្រទេសណាមួយ។

**ពន្ធដារ**
អ. taxation
បារ. imposition (f.)/ impôts (m.)

១- ប្រព័ន្ធនៃការប្រមូលពន្ធរបស់រដ្ឋាភិបាលពីអ្នកជាប់ពន្ធ សម្រាប់ចំណាយសាធារណៈ។
២- ពន្ធគ្រប់ប្រភេទ។

**ពន្ធប្រយោល/ពន្ធមិនចំពោះ**
អ. indirect tax
បារ. impôt indirect

ពន្ធលើទំនិញនិង/ឬសេវា ដែលអ្នកប្រើប្រាស់ចុងក្រោយបង់ជូនរដ្ឋ តាមរយៈអ្នកផ្គត់ផ្គង់។

**ពន្ធផ្ទាល់/ពន្ធចំពោះ**
អ. direct tax
បារ. impôt direct

ពន្ធលើប្រាក់ចំណូល ចលនទ្រព្យ អចលនទ្រព្យ... ដែលអ្នកជាប់ពន្ធត្រូវបង់ដោយផ្ទាល់ជូនរដ្ឋ។

**ពន្ធលើឈ្នួលផ្ទះនិងដី**

អ. tax on property rental

បារ. impôt sur le loyer

ពន្ធប្រមូលពីកម្មសិទ្ធិករឬសិទ្ធិវន្តរបស់កម្មសិទ្ធិករ ដែលកំណត់លើការជួលផ្ទះ អគារ រោងចក្រ រោងជាង ឃ្លាំង ព្រមទាំងដីធ្លីដែលគ្មានសំណង់ ជាដើម គិតជាភាគរយនៃប្រាក់ឈ្នួលដុល។

**ពន្ធលើប្រាក់ចំណូល**

អ. income tax

បារ. impôt sur le revenu

នៅកម្ពុជា ពន្ធដែលត្រូវបានកំណត់លើអ្នកជាប់ពន្ធនិវាសនជនចំពោះប្រាក់ចំណូលប្រភពក្នុងប្រទេសនិងប្រាក់ចំណូលប្រភពបរទេស ប៉ុន្តែចំពោះអនិវាសនជន ពន្ធលើប្រាក់ចំណូល កំណត់តែលើប្រាក់ចំណូលប្រភពក្នុងប្រទេសប៉ុណ្ណោះ។

**ពពុះ**

អ. bubble

បារ. bulle (f.)

សភាពនៃថ្លៃទំនិញ សេវា ឬ មូលបត្រ ដែលកើនឡើងខ្ពស់ហួសពីកម្រិតថ្លៃ ឬ សក្តានុពលពិតប្រាកដរបស់ទំនិញ សេវា ឬ មូលបត្រនោះក្នុងរយៈពេលជាក់លាក់មួយ។

ឧ. ថ្លៃដីនៅទីផ្សារអចលនទ្រព្យកម្ពុជាបានកើនឡើងជារបៀបពពុះនៅចន្លោះឆ្នាំ២០០៧-២០០៨ ក្នុងខណៈពេលដែលតម្រូវការអចលនទ្រព្យមានការកើនឡើងយ៉ាងគំហុក។

**ពាណិជ្ជនាម**

ឈ្មោះឬសញ្ញាសម្គាល់ឬជាឈ្មោះនិងសញ្ញាសម្គាល់សម្រាប់បញ្ជាក់និងសម្គាល់លក្ខណៈខុសៗគ្នានៃសហគ្រាសនីមួយៗ។

**ពិពិធភាព**

អ. diversity

បារ. diversité ( f. )

ភាពទីទៃ ភាពចម្រុះផ្សេងគ្នា ភាពផ្សេងគ្នានៃមូលដ្ឋានសេដ្ឋកិច្ច។

ពិពិធភាពសេដ្ឋកិច្ចជាសេដ្ឋកិច្ចដែលមានភាពចម្រុះផ្សេងគ្នានៃឧស្សាហកម្ម វិស័យនានា កម្រិតជំនាញ និង កម្រិតការងារសម្រាប់ធ្វើឱ្យសេដ្ឋកិច្ចមានវិសាលភាពធំជាងមុន ប្រសើរជាងមុន។

ឧ. ពិពិធភាពសេដ្ឋកិច្ចកម្ពុជាមិនត្រឹមតែផ្អែកទៅលើវិស័យកសិកម្ម និង វាយនភណ្ឌប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តោតទៅលើវិស័យទេសចរណ៍ និងសំណង់ផងដែរ ទើបធ្វើឱ្យសេដ្ឋកិច្ចមានមូលដ្ឋានកំណើនធំទូលាយជាងមុន។

# ភ

**ភតិកៈ**
អ. lessee
បារ. locataire (m.)/
preneur à bail

ភាគីម្ខាងនៃភតិសន្យាដែលសន្យាថានឹងបង់ថ្លៃឈ្នួលដើម្បីជាថ្នូរនឹងការទទួលបាននូវសិទ្ធិប្រើប្រាស់និងអាស្រ័យផលពីចលនវត្ថុណាមួយរបស់ភតិបតី។

**ភតិបតី**
អ. lessor
បារ. bailleur (m.)

ភាគីម្ខាងនៃភតិសន្យាដែលសន្យាថាឱ្យភតិកៈប្រើនិងអាស្រ័យផលពីវត្ថុណាមួយដោយយកថ្លៃឈ្នួល។

**ភតិសន្យា**
អ. lease
បារ. bail (m.)

១- កិច្ចសន្យាដែលភាគីម្ខាងផ្តល់វត្ថុណាមួយឱ្យភាគីម្ខាងទៀត ដើម្បីប្រើប្រាស់និងអាស្រ័យផលដោយយកថ្លៃឈ្នួលតាមលក្ខខណ្ឌដែលបានកំណត់។

២- ប្រតិបត្តិការដែលភតិបតីចុះកិច្ចព្រមព្រៀងជាមួយភតិកៈ ក្នុងនោះភតិកៈត្រូវបានផ្តល់សិទ្ធិឱ្យកាន់កាប់និងប្រើប្រាស់ចលនវត្ថុក្នុងរយៈពេលមួយដោយការបង់ថ្លៃឈ្នួលតាមគ្រាឬតាមតម្លៃសមមូល។ ភតិសន្យាត្រូវរួមបញ្ចូលទាំងភតិសន្យាបន្តផងដែរ។ (ច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុមាត្រា៤)

**ភតិសន្យាបន្ត**
អ. sublease
បារ. sous-bail ( m. )

កិច្ចសន្យាដែលភតិកៈដំបូងបានជួលទ្រព្យសកម្មពីភតិបតី រួចហើយជួលបន្តឱ្យភតិកៈមួយទៀត ដោយក្នុងនោះភតិសន្យាដំបូងនៅមានសុពលភាពដដែល។

**ភតិសន្យាហិរញ្ញវត្ថុ**
អ. finance lease
បារ. prêt financier/bail financier

ភតិសន្យាដែលភតិកៈបញ្ជាក់ច្បាស់លាស់នូវចលនវត្ថុនិងជ្រើសរើសអ្នកផ្គត់ផ្គង់ដោយខ្លួនឯង ហើយភតិបតីទិញចលនវត្ថុតាមកិច្ចព្រមព្រៀងដើម្បីជួលឱ្យភតិកៈ។

**ភាគហ៊ុន**
អ. share
បារ. action ( f. )

ឯកតានៃកម្មសិទ្ធិដែលតំណាងចំណែកនៃដើមទុនរបស់ក្រុមហ៊ុន។
ឧ. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយមានម្ចាស់ភាគហ៊ុនចំនួន១០នាក់ ដែលម្នាក់ៗកាន់កាប់ភាគហ៊ុន១០% នៃដើមទុនសរុប។

**ភាពធន់**
អ. resilience
បារ. résilience ( f. )

ភាពមាំទាំនៃមូលដ្ឋានកំណើនសេដ្ឋកិច្ច ដែលអាចប្រឈមបានទៅនឹងផលប៉ះពាល់នៃការប្រែប្រួលបរិយាកាសសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
ឧ. កម្ពុជាចាំបាច់ត្រូវពង្រីក និង ពង្រឹងមូលដ្ឋាននៃកំណើនសេដ្ឋកិច្ចបន្ថែមទៀតដើម្បីបង្កើតបាននូវភាពធន់សម្រាប់ប្រឈមនឹងវិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅពេលអនាគត។

**ភាពអាចឆ្លើយតបបាន**
អ. responsiveness

លទ្ធភាពអាចដោះស្រាយបានចំពោះហានិភ័យ ឬ វិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
២. គោលនយោបាយពង្រីកប្រព័ន្ធធារាសាស្ត្រជាភាពអាចឆ្លើយតបបាននឹងគ្រោះធម្មជាតិ ដូចជាគ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់ផង។

**ភាពអាចទុកចិត្តបាន**
អ. reliability
បារ. fiabilité (f.)

លក្ខណសម្បត្តិរបស់បុគ្គល ក្រុមហ៊ុន អង្គភាពអាជីវកម្ម ស្ថិតិ...ដែលធ្វើឱ្យកិច្ចការប្រព្រឹត្តទៅបានប្រកបដោយភាពអាចជឿជាក់បាន។

# ម

**មជ្ឈការ**
អ. centralization
បារ. centralisation ( f. )

ការគ្រប់គ្រង និង សិទ្ធិអំណាចធ្វើសេចក្ដីសម្រេចនានាខាងផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្ថិតលើថ្នាក់ដឹកនាំកំពូលនៃរចនាសម្ព័ន្ធគ្រប់គ្រង។
ឧ. រាល់ការបញ្ជាទិញលក់សន្លឹកហ៊ុននៅកម្ពុជាត្រូវធ្វើឡើងជាលក្ខណៈមជ្ឈការ ព្រោះដំណើរការនេះប្រមូលផ្ដុំតែនៅក្នុងផ្សារមូលបត្រកម្ពុជាប៉ុណ្ណោះ។

**ម៉ាក**

សញ្ញាដែលមើលឃើញ ហើយអាចសម្គាល់លក្ខណៈខុសគ្នានៃទំនិញឬសេវានៃសហគ្រាសនីមួយៗ។ ម៉ាកដែលប្រើប្រាស់សម្រាប់ទំនិញហៅថា ពាណិជ្ជសញ្ញា ហើយម៉ាកដែលប្រើប្រាស់សម្រាប់សេវាហៅថា សេវាសញ្ញា។

**ម៉ាក្រូម៉ាឃិធីងម៉ាក្រូកិច្ចទីផ្សារ**
អ. macromarketing / macro-marketing/macro marketing
បារ. macromarketing ( m. )/ macro-marketing ( m. )

សំណុំសកម្មភាពនិងដំណើរការកិច្ចទីផ្សារនៃទំនិញឬសេវាក្នុងកម្រិតប្រទេសឬសង្គមជាតិដោយមានការខុសទទួល ត្រូវសង្គម។

**ម៉ាក្រូសេដ្ឋកិច្ច**
អ. macroeconomics
បារ. macroéconomie ( f. )

ផ្នែកមួយនៃវិទ្យាសាស្ត្រសេដ្ឋកិច្ចសិក្សាអំពីប្រព័ន្ធសេដ្ឋកិច្ចជាតិទាំងមូល ដែលផ្ដោតទៅលើចំណូលជាតិ កំណើនសេដ្ឋកិច្ច និកម្មភាពអតិផរណា ជាដើម។

**ម៉ាស៊ីនទទួលប្រាក់បញ្ញើ**
អ. cash deposit machine ( CDM )
បារ. machine de dépôt en espèces

ម៉ាស៊ីនអេឡិចត្រូនិកស្វ័យប្រវត្តដែលអនុញ្ញាតឱ្យអតិថិជនដាក់ប្រាក់បញ្ញើចូលក្នុងគណនីបានគ្រប់ពេលវេលាដោយការប្រើប្រាស់បណ្ណអេធីអឹម ( កាតអេធីអឹម ) និងលេខសម្ងាត់ផ្ទាល់ខ្លួន។

**ម៉ាស៊ីនអេធីអឹម/ម៉ាស៊ីនប្រតិបត្តិការធនាគារស្វ័យប្រវត្ត**
អ. automatic teller machine ( ATM )
បារ. guichet automatique bancaire ( GAB )

ម៉ាស៊ីនអេឡិចត្រូនិកស្វ័យប្រវត្តដែលអតិថិជនអាចធ្វើប្រតិបត្តិការដកប្រាក់ ដាក់ប្រាក់ ផ្ទេរប្រាក់ ទូទាត់។ល។ បានគ្រប់ពេលវេលាដោយការប្រើប្រាស់បណ្ណអេធីអឹម ( កាតអេធីអឹម ) និងលេខសម្ងាត់ផ្ទាល់ខ្លួន។

**មីក្រូម៉ាឃិធីង**
អ. micromarketing/micro marketing
បារ. micromarketing/ micro marketing

សំណុំសកម្មភាពនិងដំណើរការកិច្ចទីផ្សាររបស់សហគ្រាសណាមួយ អំពីផលិតផលឬសេវារបស់ខ្លួនឆ្ពោះទៅក្រុមអតិថិជនជាក់លាក់។

**មីក្រូសហគ្រាស**

អ. micro enterprise

បារ. micro-entreprise

សហគ្រាសដែលមានទុនសមមូលសរុបតិចជាង ២០០លានរៀល ឬ មានបុគ្គលិកពេញម៉ោងតិចជាង១០នាក់ ឬមានផលរបរប្រចាំឆ្នាំតិចជាង ២៥០លានរៀល។

តួលេខនេះប្រើក្នុងវិស័យឧស្សាហកម្មនិងសិប្បកម្ម ដែលមានអត្រាប្តូរប្រាក់ ១ដុល្លារ ស្មើនឹង៤ ០០០ រៀល។

**មីក្រូសេដ្ឋកិច្ច**

អ. microeconomics

បារ. microéconomie ( f. )

ផ្នែកមួយនៃវិទ្យាសាស្ត្រសេដ្ឋកិច្ចសិក្សាអំពីឥរិយាបថរបស់បុគ្គល ក្រុមហ៊ុនឬស្ថាប័នដែលពាក់ព័ន្ធទៅនឹងជម្រើសនិងការសម្រេចចិត្តក្នុងការឆ្លើយតបនឹងថ្លៃទំនិញនិងតម្រូវការក្នុងទីផ្សារ។

**មូលធន**

អ. capital

បារ. capital ( m. )

ដើមទុន ឬ ធនធានទាំងឡាយដែលរួមចំណែកដល់ផលិតកម្ម ឬ ការវិនិយោគ។ មូលធនជាតម្លៃធនធាន ឬ ភាគហ៊ុនរបស់ម្ចាស់ ហ៊ុន ឬ ក្រុមហ៊ុនមួយសម្រាប់បង្កើត ឬ ពង្រីកផលិតកម្ម ឬការវិនិយោគ។

ឧ. ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញបានបង្កើនមូលធនជាសាច់ប្រាក់ចំនួន១៥% តាមរយៈការបោះផ្សាយលក់មូលបត្រជាសាធារណៈនៅខែមេសា ឆ្នាំ២០១២ ដើម្បីពង្រីកគម្រោងវិនិយោគរបស់ខ្លួន។

**មូលធននិយម**
អ. capitalism
បារ. capitalisme ( m. )

ប្រព័ន្ធសេដ្ឋកិច្ចមួយដែលនៅក្នុងនោះមធ្យោបាយផលិតកម្មជាកម្មសិទ្ធិរបស់ម្ចាស់ទុនឯកជនដែលធ្វើប្រតិបត្តិការដើម្បីស្វែងរកប្រាក់ចំណេញ។

**មូលធនមនុស្ស**
អ. human capital

បណ្តុំនៃសមត្ថភាព ចំណេះដឹង ជំនាញ បទពិសោធ និង ភាពច្នៃប្រឌិតរបស់មនុស្សដែលអាចផលិតចេញជាតម្លៃសេដ្ឋកិច្ចបាន។

ឧ. រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពខ្ពស់លើការអភិវឌ្ឍមូលធនមនុស្សតាមរយៈការពង្រឹងគុណភាពវិស័យអប់រំ បណ្តុះបណ្តាលសមត្ថភាព និង ជំនាញវិជ្ជាជីវៈរបស់យុវជន និង បុគ្គលិកកម្មករ។

**មូលប្បទានបត្រ/សែក**
អ. cheque
បារ. chèque ( m. )

បណ្ណបោះពុម្ពដោយគ្រឹះស្ថានហិរញ្ញវត្ថុណាមួយដែលនៅពេលម្ចាស់គណនីចុះហត្ថលេខាលើបណ្ណនោះ គ្រឹះស្ថានហិរញ្ញវត្ថុសាមីត្រូវទូទាត់ប្រាក់ឱ្យអ្នកត្រូវទទួលទៅតាមលក្ខខណ្ឌ។

**ម្ចាស់បំណុល**
អ. debtee
បារ. créancier ( m. )

បុគ្គលដែលគេត្រូវសងបំណុល។

# យ

**យន្តកម្ម**
អ. mechanization
បារ. mécanisation ( f. )

ការប្រើប្រាស់គ្រឿងយន្តក្នុងផលិតកម្ម និងសេវាកម្ម។

**យន្តូបនីយកម្ម**
អ. mechanization
បារ. mécanisation ( f. )

ដំណើរការរៀបចំឱ្យមានការប្រើប្រាស់គ្រឿងយន្តក្នុងដំណើរការផលិតកម្ម និងសេវាកម្មជំនួសការប្រើកម្លាំងមនុស្ស ឬ សត្វ។

# រ

**រតនាគារជាតិ**
អ. national treasury
បារ. trésor national

ស្ថាប័នជាតិទទួលបន្ទុកជាបេឡាធិការនិងគណនេយ្យករសាធារណៈ។

**របាំងធុរកិច្ច**
អ. business barrier

កត្តារារាំង ឬ ឧបសគ្គដល់អង្គភាពអាជីវកម្មក្នុងការចូលក្នុងទីផ្សារ ឬចេញពីទីផ្សារ។ កត្តាទាំងនោះមានដូចជា ការចំណាយចាប់ផ្ដើមអាជីវកម្ម ថ្លៃដើមផលិតកម្ម លក្ខខណ្ឌច្បាប់ បទបញ្ញត្តិ ការប្រកួតប្រជែងកម្មសិទ្ធិបញ្ញា កម្រិតបច្ចេកវិទ្យាជាដើម។ ឧ. ការចំណាយខ្ពស់លើការចាប់ផ្ដើមបើកអាជីវកម្មជារបាំងធុរកិច្ចមួយ ដែលធ្វើឱ្យចំនួនក្រុមហ៊ុនកើនឡើងតិចតួចនៅក្នុងប្រទេស។

**របាំងមិនមែនពន្ធ**
អ. non-tariff barriers

កត្តារារាំង ឬ ឧបសគ្គក្រៅពីពន្ធ ដែលរឹតត្បិតការធ្វើពាណិជ្ជកម្មអន្តរជាតិ មានដូចជាបទដ្ឋានស្តង់ដាគុណភាព អនាម័យនិងបរិស្ថាន ការបំពេញបែបបទគយ កូតា ជាដើម។

**របៀងឧស្សាហកម្ម**
អ. industrial corridor

ទីតាំងភូមិសាស្ត្រជាក់លាក់មួយដែលជាច្រកឬផ្លូវសម្រាប់តភ្ជាប់ទំនាក់ទំនងរវាងប្រទេសឬតំបន់នានាដើម្បីជំរុញការអភិវឌ្ឍឧស្សាហកម្ម។

**រូបិយបណ្ណ**
អ. currency
បារ. devise ( f. )

រូបិយវត្ថុនៃប្រទេសមួយដែលគិតដោយធៀបនឹងរូបិយវត្ថុនៃប្រទេសផ្សេងទៀត។ ជាទូទៅ ពាក្យនេះប្រើសម្រាប់ចង្អុលបង្ហាញរូបិយវត្ថុ របស់ប្រទេសក្រៅដែលមិនមែនជារូបិយវត្ថុជាតិ។
ឧ. រូបិយបណ្ណសំខាន់ៗនៅប្រទេសកម្ពុជាបច្ចុប្បន្នមាន ដុល្លារ អឺរ៉ូ យ៉េន ...។

**រូបិយវត្ថុ**
អ. money
បារ. monnaie ( f. )

ឧបករណ៍ផ្លូវការដែលចេញផ្សាយដោយធនាគារជាតិ និង ទទួលស្គាល់ដោយរដ្ឋាភិបាលរបស់ប្រទេសមួយប្រើប្រាស់សម្រាប់វាស់វែងតម្លៃ ដោះដូរ និងសន្សំ។
រូបិយវត្ថុ មានដូចជា កាក់លោហៈ ក្រដាសប្រាក់ មូលប្បទានបត្រ ជាដើម។
ឧ. ប្រាក់រៀលជារូបិយវត្ថុរបស់ព្រះរាជាណាចក្រកម្ពុជា។

# ល

**លក្ខណៈសញ្ញា**

អ. badge

បារ. insigne ( m. )

ផ្លាកសញ្ញាសម្គាល់សក្តិយស តួនាទី។

ឧ. លក្ខណៈសញ្ញានៃអ្នកបើកយន្តហោះ។

**លុយរាប់**

ប្រាក់ដែលជាទូទៅអ្នកខ្ចីត្រូវសងជាចំណែកៗស្មើរៀងរាល់ថ្ងៃទាំងដើម ទាំងការ ទៅម្ចាស់លុយតាមការព្រមព្រៀង។

# វ

**វិការភាពផ្សារ**
អ. market distortion
បារ. distorsion du marché

ដំណើរខុសពីសភាពដើម ឬ ទម្រង់ដើមនៃដំណើរការផ្សារ ដោយសារអន្តរាគមន៍របស់រូបវន្តបុគ្គល ឬ នីតិបុគ្គលណាមួយ។

**វិច្ឆិន្នភាព**
អ. severability
បារ. divisibilité (f.)/ séparabilité (f.)

ភាពនៃការអាចអនុវត្តបាននៃគម្រោងវិនិយោគ ទោះបីជាប្រការណាមួយនៃកិច្ចព្រមព្រៀងវិនិយោគនោះ មិនអាចអនុវត្តបានក៏ដោយ។

**វិត្ថារកម្ម**
អ. expansion
បារ. expansion (f.)/ augumentation (f.)

ការបង្កើន ការបន្ថែម ការពង្រីកទំហំ ចំនួន ឬ បរិមាណចំណាយ។ក្នុងវិស័យសេដ្ឋកិច្ច«វិត្ថារកម្ម» មានន័យថា ការបង្កើន ឬការកើនឡើងនៃកម្រិតចំណាយដើម្បីបង្កើនសកម្មភាពសេដ្ឋកិច្ច និងទំនិញ និងសេវាកម្មនៅក្នុងទីផ្សារ។ ជាទូទៅ វិត្ថារកម្មសេដ្ឋកិច្ច(economic expansion) កើតឡើងនៅខណៈពេលដែលមានការប្រែប្រួលនូវចង្វាក់ផលិតកម្មនិងការប្រើប្រាស់ធនធានសម្រាប់ជំរុញឱ្យសេដ្ឋកិច្ចងើបឡើងវិញនិងមានការរីកចម្រើន។

វិបត្តិនៃការកម្មសេដ្ឋកិច្ចអាចកើតឡើងដោយសារកត្តាខាងក្នុងដូចជា គោលនយោបាយសារពើពន្ធ គោលនយោបាយរូបិយវត្ថុ។ល។ និង កត្តាខាងក្រៅដូចជា ការប្រែប្រួលអាកាសធាតុ បច្ចេកវិទ្យា។ល។

ឧ. កម្ពុជាធ្វើវិត្តារកម្មសេដ្ឋកិច្ចរបស់ខ្លួន ដោយបង្កើនចំណាយថវិកាជាតិទៅលើវិស័យកសិកម្ម និងធារាសាស្ត្រ សម្រាប់ពង្រីកផលិតផលកសិកម្ម និងមូលដ្ឋានកំណើនសេដ្ឋកិច្ច។

**វិមជ្ឈការ**

អ. decentralization

បារ. décentralisation ( f. )

ការផ្ទេរសិទ្ធិអំណាច ធនធានហិរញ្ញវត្ថុ និងការទទួលខុសត្រូវពីស្ថាប័នថ្នាក់លើទៅស្ថាប័នថ្នាក់ក្រោមដើម្បីបំពេញមុខងារ និងភារកិច្ចនានា។

ឧ. ការដាក់ឱ្យអនុវត្តនូវផែនការយុទ្ធសាស្ត្រថវិកាថវិកាកម្មវិធីនិងអង្គភាពថវិកា មានគោលបំណងផ្លាស់ប្តូរជាបណ្តើរៗនូវប្រព័ន្ធគ្រប់គ្រងថវិកាកម្ពុជាពីការផ្តោតលើធាតុចូលនិងមជ្ឈការ ទៅផ្តោតលើលទ្ធផល និង វិមជ្ឈការដែលត្រូវសម្រេចឱ្យបាននៅឆ្នាំ២០២០។

**វិសម្ពាធ**
អ. depression
បារ. dépression (f.)

ការធ្លាក់ចុះដុនដាបនៃសេដ្ឋកិច្ច ដែលបណ្តាលឱ្យផលិតផលក្នុងស្រុកសរុបធ្លាក់ចុះខ្លាំង និងអាចអូសបន្លាយក្នុងរយៈពេលវែងដែលក្នុងនោះ ការផ្គត់ផ្គង់និងតម្រូវការមានការថយចុះយ៉ាងខ្លាំងបើធៀបនឹងដំណាក់កាលផ្សេងទៀតនៃវដ្តសេដ្ឋកិច្ច។
ឧ. វិសម្ពាធធ្ងន់ធ្ងរនៃសេដ្ឋកិច្ចពិភពលោកបានផ្ទុះឡើងនៅឆ្នាំ១៩២៩ក្រោយការដួលរលំនៃផ្សារហ៊ុនរបស់អាម៉េរិក។

**វិសហមជ្ឈការ**
អ. deconcentration
បារ. déconcentration (f.)

ការផ្ទេរមុខងារមួយចំនួនរបស់ស្ថាប័នថ្នាក់លើទៅស្ថាប័នថ្នាក់ក្រោមឱ្យទទួលខុសត្រូវលើការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងនាមស្ថាប័នថ្នាក់លើនោះ។
ឧ. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានធ្វើវិសហមជ្ឈការជូនមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត នូវមុខងារត្រួតពិនិត្យការចំណាយថវិការបស់អង្គភាពរដ្ឋថ្នាក់រាជធានី ខេត្ត ក្នុងនាមក្រសួង។

**វេទយិតភាព**
អ. sensitivity
បារ. sensibilité (f.)

ភាពងាយប្រែប្រួលនៃសកម្មភាពសេដ្ឋកិច្ចនៅពេលដែលមានការកើតឡើងនូវហេតុបច្ច័យអ្វីមួយ (គម្រោងការគោលនយោបាយ...)។
ឧ. កំណើនសេដ្ឋកិច្ចមានវេទយិតភាពដោយសារបម្រែបម្រួលអត្រាការប្រាក់ ឬ អត្រាអតិផរណា។

# ស

**សក្តិសិទ្ធិភាព**
អ. efficiency
បារ. efficacité ( f. )

ការប្រព្រឹត្តទៅឬការបំពេញការងារដែលសន្សំសំចៃចំណាយពេលតិច។
ការប្រព្រឹត្តទៅ ឬ ការបំពេញការងារដែលខិតខំប្រឹងប្រែងតិចតួចតែទទួលបានលទ្ធផលគាប់ប្រសើរ។
ឧ. សក្តិសិទ្ធិភាពនៃបច្ចេកវិទ្យាកើតឡើងនៅពេលដែលការកើនឡើងនៃបរិមាណផលិតផលមិនត្រូវការវត្ថុធាតុដើមបន្ថែមទៀតដើម្បីផលិត។

**សង្វេបកម្ម**
អ. recession
បារ. récession ( f. )

ការធ្លាក់ចុះនៃសេដ្ឋកិច្ចដែលបណ្តាលឱ្យផលិតផលក្នុងស្រុកសរុបធ្លាក់ចុះនិង អូសបន្លាយក្នុងរយៈពេល៦ខែទៅ១ឆ្នាំ។
ឧ. វិបត្តិហិរញ្ញវត្ថុនៅអាស៊ីក្នុងឆ្នាំ១៩៩៧ ធ្វើឱ្យមានសង្វេបកម្មសេដ្ឋកិច្ច។

**សង្គតិភាព**

អ. consistency

បារ. consistance (f.)

ការរាប់អានគ្នា ការរួបរួមគំនិតគ្នា ការជួបប្រសព្វគ្នា សេចក្តីស្មោះស្មើទៅវិញទៅមករកគ្នា។

ក្នុងន័យសេដ្ឋកិច្ច ពាក្យនេះប្រើសំដៅដល់ភាពចុះសម្រុងគ្នារវាងវិធីភាពផ្សេងគ្នា។

ឧ. រាជរដ្ឋាភិបាលទទួលស្គាល់នូវភាពចាំបាច់នៃការធានាសង្គតិភាពនៃឋានានុក្រម តួនាទី ខ្លឹមសារ និង លំដាប់លំដោយនៃការអនុវត្តរវាង«យុទ្ធសាស្រ្តចតុកោណ»ជាមួយនឹង«ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ»ក៏ដូចជាយុទ្ធសាស្រ្តអភិវឌ្ឍន៍តាមវិស័យព្រមទាំងជាមួយនឹងឯកសារដែលមានលក្ខណៈជាផែនការគោលនយោបាយកម្មវិធីវិនិយោគនិងថវិកាជាតិ។

**សញ្ញាណប័ដ**

ដំបារឬបន្ទះស្លាក(...) ដូច្នេះពាក្យនេះក៏មិនអាចគ្របដណ្តប់លើ«បដា»បានដែរ : គួរយើងយកពាក្យ«រូបសញ្ញា»វិញដើម្បីគ្របដណ្តប់លើសញ្ញាផ្សេងៗដែលមាន«បដា»ផង ហើយរូបសញ្ញាមាន : ផ្លាកយីហោ, ផ្លាកពាណិជ្ជកម្ម, ពាណិជ្ជនាម, ម៉ាក, និមិត្តសញ្ញា, លក្ខណសញ្ញា, បដា, ប៉ង់កាត, ប៉ាណូ, អាហ្វីស, ស្ប៉ុត, បណ្ណប្រកាស, អក្សរចារឹកនៅតាមទីសាធារណៈ។ល។

**សនិទានកម្មចំណាយ**
អ. expenditure
rationalization

ការវិភាគពិចារណាដោយសមហេតុផលក្នុងការសម្រេចចិត្តលើមុខចំណាយណាមួយ។ ចំពោះថវិកាជាតិសនិទានកម្មចំណាយ គឺជាចំណាយប្រកបដោយប្រសិទ្ធភាពខ្ពស់ ធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងនិរន្តរភាពសារពើពន្ធ។

**សនិទានភាព**
អ. rationality
បារ. rationalité ( f. )

គោលការណ៍ ឬភាពសមហេតុផលដែលឈរលើមូលដ្ឋាននៃការពិចារណាហ្មត់ចត់និងត្រឹមត្រូវ។
ឧ. ក្នុងការគ្រប់គ្រងថវិការដ្ឋាភិបាលចាំបាច់ត្រូវមានសនិទានភាពចំពោះចំណាយតាមរយៈការធ្វើអាទិភាវូបនីយកម្មថវិកានៃចំណាយចរន្តនិងចំណាយមូលធន។

**សន្លឹកហ៊ុន**
អ. stock
បារ. stock ( m. )/
valeurs ( f. pl. )

បណ្ណមួយប្រភេទមានតម្លៃកំណត់មួយដែលបោះផ្សាយដោយក្រុមហ៊ុនសាជីវកម្ម ឬ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និង ជាទូទៅអាចជួញដូរនៅលើទីផ្សារហិរញ្ញវត្ថុ។
ឧ. តម្លៃសន្លឹកហ៊ុនរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញបានកើនឡើងជិត៥០%នៅថ្ងៃដំបូងនៃការដាក់លក់ជាផ្លូវការនៅលើផ្សារមូលបត្រកម្ពុជា។

**សហគ្រាស**
អ. enterprise
បារ. entreprise ( f. )

អង្គភាពឬគ្រឹះស្ថានដែលមានគោលដៅស្វែងរកប្រាក់ចំណេញ រួមមាន សហគ្រាសសាធារណៈ និងសហគ្រាសឯកជន រួមទាំងគ្រឹះស្ថានហិរញ្ញវត្ថុ និងសហគ្រាសធុនតូចនិងមធ្យម ព្រមទាំងមីក្រូសហគ្រាសផងដែរ។

**សហគ្រាសធុនតូច**
អ. small enterprise
បារ. petite entreprise

សហគ្រាសដែលមានទុនសមមូលចន្លោះពី២០០លានរៀលទៅក្រោម ២៥០លានរៀល ឬមានបុគ្គលិកពេញម៉ោងចន្លោះពី១១ដល់៥០នាក់ ឬមានផលរបរប្រចាំឆ្នាំចាប់ពី២៥០លានរៀលដល់៧០០លានរៀល។ តួលេខនេះប្រើក្នុងវិស័យឧស្សាហកម្មនិងសិប្បកម្ម ដែលមានអត្រាប្តូរប្រាក់ ១ដុល្លារ ស្មើនឹង៤ ០០០ រៀល។

**សហគ្រាសធុនធំ**
អ. large enterprise
បារ. grande entreprise

សហគ្រាសដែលមានទុនសមមូលចាប់ពី២ ០០០លានរៀលឡើងទៅ ឬមានបុគ្គលិកពេញម៉ោងលើសពី១០០នាក់ឬមានផលរបរប្រចាំឆ្នាំលើសពី២ ០០០ លានរៀល។
តួលេខនេះប្រើក្នុងវិស័យឧស្សាហកម្មនិងសិប្បកម្ម ដែលមានអត្រាប្តូរប្រាក់ ១ដុល្លារ ស្មើនឹង៤ ០០០ រៀល។

**សហគ្រាសធុនមធ្យម**
អ. medium enterprise
បារ. moyenne entreprise

សហគ្រាសដែលមានទុនសមមូលចន្លោះពី២៥០ លានរៀលទៅក្រោម២ ០០០លានរៀល ឬមានបុគ្គលិកពេញម៉ោងចន្លោះពី៥១ដល់១០០ នាក់ ឬមានផលរបរប្រចាំឆ្នាំ ចាប់ពី៧០០លានរៀល ដល់២ ០០០ លានរៀល។ តួលេខនេះប្រើក្នុងវិស័យឧស្សាហកម្មនិងសិប្បកម្ម ដែលមានអត្រាប្តូរប្រាក់ ១ដុល្លារ ស្មើនឹង៤ ០០០ រៀល។

**សហគ្រាសសាធារណៈ**
អ. public enterprise
បារ. entreprise publique

សហគ្រាសមានដើមទុនទាំងអស់ឬភាគច្រើនជារបស់រដ្ឋមានទម្រង់ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ក្រុមហ៊ុនរដ្ឋ និងក្រុមហ៊ុនចម្រុះ ដែលក្នុងនោះ រដ្ឋកាន់កាប់លើសពី៥០% នៃដើមទុនក្រុមហ៊ុនឬសិទ្ធិបោះឆ្នោត។

**សហគ្រាសឯកជន**
អ. private enterprise
បារ. entreprise privée

អង្គភាពអាជីវកម្មមិនមែនជាកម្មសិទ្ធិរបស់រដ្ឋ ដែលបង្កើតឡើងដើម្បីស្វែងរកប្រាក់ចំណេញ។

**សហគ្រាសឯកបុគ្គល**
អ. sole proprietorship
បារ. entreprise individuelle

សហគ្រាសអាជីវកម្មដែលជាកម្មសិទ្ធិ១០០%របស់រូបវន្តបុគ្គលណាម្នាក់។
(ក្នុងច្បាប់ស្ដីពីសាររពើពន្ធ ប្ដី ប្រពន្ធ និងកូនក្នុងបន្ទុកត្រូវចាត់ទុកជារូបវន្តបុគ្គលតែម្នាក់)

**សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត**
អ. single member private limited company
បារ. entreprise unipersonnelle à responsabilité limitée (EURL)

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតដែលមានម្ចាស់ភាគហ៊ុនតែម្នាក់។

**សហគ្រិនភាព**
អ. entrepreneurship
បារ. esprit d'entreprise

សមត្ថភាពនិងឆន្ទៈ ដើម្បីបង្កើត ចាត់ចែង និងគ្រប់គ្រងអាជីវកម្មណាមួយដែលអាចមានហានិភ័យក្នុងគោលបំណងទទួលបានប្រាក់ចំណេញនិងជានាបាននូវសុខុមាលភាពសង្គម។ ចរិតនៃសហគ្រិនភាពកំណត់ដោយនវានុវត្តន៍ និងការប្រឈមនឹងហានិភ័យ។

**សហថាមពល/សំថាមពល**
អ. synergy
បារ. synergie ( f. )

ការធ្វើកិច្ចការរួមគ្នា ឬ ការរួមបញ្ចូលកម្លាំងគ្នារវាងប្រទេស ក្រុមហ៊ុន ស្ថាប័ន ភ្នាក់ងារ ឬ បុគ្គលពីរ ឬច្រើននឹងទទួលបានលទ្ធផលខ្ពស់ជាងផលបូកនៃលទ្ធផលរបស់ប្រទេស ក្រុមហ៊ុន ស្ថាប័ន ភ្នាក់ងារ ឬបុគ្គលនីមួយៗបញ្ចូលគ្នា។

ឧ. ការកើនឡើងនៃភាពទាក់ទាញវិនិយោគ និងទេសចរណ៍ក្នុងតំបន់អាស៊ាន គឺជាលទ្ធផលនៃសហថាមពល/សំថាមពលដែលកើតចេញពីការធ្វើសមាហរណកម្មកាន់តែជិតស្និទ្ធក្នុងចំណោមប្រទេសជាសមាជិក។

**សាកលភាវូបនីយកម្ម**
អ. globalization
បារ. mondialisation ( f. )/ globalisation ( f. )

ការរីកចម្រើននៃទំនាក់ទំនងជាសាកលលើវិស័យសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងនយោបាយដោយសារការរីកចម្រើននៃប្រព័ន្ធបច្ចេកវិទ្យាទូរគមនាគមន៍ និងការអនុវត្តនូវសេរីភាវូបនីយកម្មសេដ្ឋកិច្ចនិងពាណិជ្ជកម្ម។

ការណ៍នេះស្តែងឡើងតាមរយៈពាណិជ្ជកម្ម ការវិនិយោគបរទេស ការផ្ទេរបច្ចេកវិទ្យា លំហូរនៃមូលធននិងកម្លាំងពលកម្ម។

ឧ. ពិភពលោកបច្ចុប្បន្ននេះបានឈានចូលទៅយុគសម័យនៃសាកលភាវូបនីយកម្ម។

**សិនិទ្ធភាព**
អ. cohesion
បារ. cohésion (f.)

ភាពផ្សារភ្ជាប់គ្នា ភាពអាចរួមរស់ជាមួយគ្នា និងសាមគ្គីភាព ក្នុងចំណោមប្រទេស ស្ថាប័ន ឬបុគ្គល។

ឧ. សមាគមអាស៊ានកំពុងព្យាយាមកាត់បន្ថយគម្លាតនៃការអភិវឌ្ឍនៅក្នុងចំណោមប្រទេសសមាជិក ដើម្បីក្លាយជាសហគមន៍មួយដែលមានសិនិទ្ធភាពអាចរួមរស់ជាសហគមន៍មានវាសនាតែមួយ។

**សុខដុមនីយកម្ម**
អ. harmonization
បារ. harmonisation (f.)

ការកែសម្រួលភាពផ្សេងៗគ្នា និង/ឬ ភាពមិនស៊ីចង្វាក់គ្នាដែលពាក់ព័ន្ធនឹងការវាស់វែង វិធីសាស្ត្រ នីតិវិធី កាលវិភាគ លក្ខណៈបច្ចេកទេស ឬ ប្រព័ន្ធ ដើម្បីធ្វើឱ្យមានឯកភាព ឬ មានភាពសមស្រប សម្រាប់ទាំងអស់គ្នា។

**សេញ៉រិច**
អ. seigniorage
បារ. seigneuriage (m.)

ប្រាក់ចំណូលដែលរដ្ឋាភិបាលបានពីការបោះពុម្ពរូបិយវត្ថុ ជាពិសេសគឺភាពខុសគ្នារវាងថ្លៃដើមនៃការផលិតរូបិយវត្ថុនិងថ្លៃចារឹកនៅលើរូបិយវត្ថុនោះ។

**សេដ្ឋកិច្ចក្រៅប្រព័ន្ធ**
អ. informal economy
បារ. économie informelle

ប្រព័ន្ធនៃការធ្វើពាណិជ្ជកម្ម ឬ ការដោះដូរទំនិញ និង សេវា ដែលច្បាប់មិនតម្រូវឱ្យចុះបញ្ជី។ សេដ្ឋកិច្ចក្រៅប្រព័ន្ធផ្តល់នូវការបង្កើតមុខរបរការងារធ្វើ និងប្រាក់ ចំណូល ប៉ុន្តែ អាចបង្កឱ្យមានផលវិបាកក្នុងការគ្រប់គ្រងបរិស្ថាន សុវត្ថិភាពចំណី អាហារ ការប្រមូលពន្ធ ជាដើម។
ឧ. ការលក់ដូរតាមដងផ្លូវជាសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

**សេដ្ឋកិច្ចបៃតង**
អ. green economy
បារ. économie verte

សេដ្ឋកិច្ចដែលឈរលើមូលដ្ឋាននៃការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និង មិនប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន( ធម្មជាតិ មនុស្ស វប្បធម៌ )។

**សេដ្ឋកិច្ចពុទ្ធិ**
អ. knowledge economy

សេដ្ឋកិច្ចដែលប្រព័ន្ធនៃការប្រើប្រាស់ និងផលិតកម្មផ្អែកលើមូលធនបញ្ញា។
ឧ. សេដ្ឋកិច្ចពុទ្ធិបាននិងកំពុងរួមចំណែកយ៉ាងធំក្នុងសកម្មភាពសេដ្ឋកិច្ចរបស់ប្រទេសអភិវឌ្ឍ។

**សេរីភាពសេដ្ឋកិច្ច**
អ. economic freedom
បារ. liberté économique

សេរីភាពក្នុងការជ្រើសរើស និងការធ្វើសេចក្តីសម្រេចចិត្តក្នុងការផលិត ការលក់ ការទិញ និងការប្រើប្រាស់ ដោយគោរពសិទ្ធិអ្នកដទៃ។
ឧ. នៅក្នុងសេដ្ឋកិច្ចទីផ្សារ អតិថិជនមានសេរីភាពសេដ្ឋកិច្ចពេញលេញ ព្រោះគេអាចទិញលក់អ្វីក៏បានដោយគ្មានការកំហិតកំណត់។

**សេវាធនាគារចល័ត/ធនាគារកិច្ចចល័ត**
អ. mobile banking
បារ. service bancaire mobile

សេវាផ្តល់ដោយធនាគារឬគ្រឹះស្ថានហិរញ្ញវត្ថុដែលអនុញ្ញាតឱ្យអតិថិជនអាចធ្វើប្រតិបត្តិការហិរញ្ញវត្ថុពីចម្ងាយដោយប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកចល័ត ដូចជា ទូរសព្ទដៃ កុំព្យូទ័រ ជាដើម និងដោយប្រើកម្មវិធីរបស់ធនាគារឬគ្រឹះស្ថានហិរញ្ញវត្ថុនោះ។

**ស្ប៉ុត**
អ. spot
បារ. spot ( m. )

អត្ថបទខ្លីសម្រាប់ឃោសនាពាណិជ្ជកម្ម, អប់រំ,...។

**ស្លាក**

សំបុត្រជាកំណត់តូចៗ ជាគ្រឿងសម្គាល់ឈ្មោះជាដើម; ឆ្នោត; ទីវ; ខ្នាច់ : សរសេរស្លាក, បិទ ស្លាកជាសម្គាល់; ចាប់ស្លាក; ដាក់ស្លាកជាសម្គាល់កុំឱ្យច្រឡំ។ (វចនានុក្រមសម្ដេច ជួន ណាត)

ដោយយោងទៅលើនិយមន័យនៃពាក្យខាងលើ «ស្លាក»មិនអាចប្រើជំនួស«ផ្លាក»បានទេ ពីព្រោះវាជា«កំណត់តូចៗ»រីឯ«ផ្លាកសញ្ញា»ដែលមានលក្ខណៈរឹងមិនអាចគ្របដណ្តប់លើ«បដា»ដែលមានលក្ខណៈទន់បានឡើយ។

# ហ

**ហិរញ្ញប្បទាន**

អ. financing

បារ. financement (m.)

ការផ្តល់ហិរញ្ញវត្ថុ ការឱ្យខ្ចី ការផ្តល់ប្រាក់ ការផ្តល់ទុន ឬ ការផ្តល់ឱ្យនូវធនធានសម្រាប់ទ្រទ្រង់ដំណើរការអនុវត្តគម្រោងធុរកិច្ចណាមួយ។

ដំណើរនៃការធ្វើហិរញ្ញប្បទាន គឺជាប់ពាក់ព័ន្ធទាំងអ្នកផ្តល់និងអ្នកទទួលឬអ្នកសុំខ្ចី។

ដូច្នេះក្នុងការអនុវត្តជាក់ស្តែងពាក្យ«ហិរញ្ញប្បទាន» គឺសំដៅដល់ការផ្តល់និងការទទួលប្រាក់ឬមូលនិធិសម្រាប់គាំទ្រដំណើរការគម្រោងធុរកិច្ចអ្វីមួយ។

តាមទស្សនាទានទំនើបពាក្យ«ហិរញ្ញប្បទាន» មានពីរប្រភេទគឺ ហិរញ្ញប្បទានទ្រព្យម្ចាស់និងហិរញ្ញប្បទានបំណុល(equity financing and debt financing)។

ហិរញ្ញប្បទានទ្រព្យម្ចាស់ គឺ សំដៅដល់ការកៀរគរធនធានហិរញ្ញវត្ថុតាមរយៈការបោះផ្សាយនិងលក់នូវមូលបត្រទ្រព្យម្ចាស់ (equity securities) ដូចជា សន្លឹកហ៊ុនជាដើម។

ចំណែកឯហិរញ្ញប្បទានបំណុល គឺសំដៅដល់ការកៀរគរធនធានហិរញ្ញវត្ថុ តាមរយៈការបោះពុម្ពផ្សាយនិងលក់នូវមូលបត្របំណុល(debt securities)ដូចជា សញ្ញាបណ្ណ និង បណ្ណបំណុលដទៃទៀតនៅក្នុងទីផ្សារហិរញ្ញវត្ថុឬផ្សារទុន។

**ហិរញ្ញប្បទានផ្ទាល់**

អ. direct financing

បារ. financement direct

ការផ្តល់ធនធានហិរញ្ញវត្ថុពីអ្នកផ្តល់ទៅអ្នកទទួល ដោយមិនចាំបាច់ឆ្លងកាត់អន្តរការីហិរញ្ញវត្ថុ។

**ហិរញ្ញប្បទានមិនផ្ទាល់**

អ. indirect financing

បារ. financement indirect

ការផ្តល់ធនធានហិរញ្ញវត្ថុពីអ្នកផ្តល់ទៅអ្នកទទួល តាមរយៈអន្តរការីហិរញ្ញវត្ថុ។

# ឡ

**ឡូហ្ស៊ីស្ទិក**
អ. logistics

ដំណើរការ ឬ សកម្មភាពនៃការគ្រប់គ្រងធនធាន (ម្ហូប អាហារ សម្ភារៈ បរិក្ខារ សត្វ។ល។) ដោយទទួលរក្សាទុក និង បញ្ជូនទៅកាន់ទីតាំងណាមួយដែលគេតម្រូវ។

ដំណើរការ ឬ សកម្មភាពក្នុងប្រព័ន្ធឡូហ្ស៊ីស្ទិក មានការវេចខ្ចប់ ការដឹកជញ្ជូន ការស្តុកទុកក្នុងឃ្លាំង ជាដើម។

ឧ. ក្រុមហ៊ុន ឌីអេចអិល (DHL) ជាក្រុមហ៊ុនលំដាប់ពិភពលោកដែលទទួលធ្វើសេវាឡូហ្ស៊ីស្ទិក ដោយទទួលរៀបចំដឹកជញ្ជូនទំនិញឆ្លងពីប្រទេសមួយទៅប្រទេសផ្សេងទៀត។

**អក្សរចារឹក**
អ. notice-board
បារ. écriteau ( m. )

អក្សរដែលគេចារនៅលើខ្លោងទ្វារ, ក្បាលស្ពាន, គោលសីមាជាដើម។

**អង្គភាពថវិកា**
អ. budget entity
បារ. entité budgétaire ( f. )

អង្គភាពឬស្ថាប័នដែលទទួលបានសិទ្ធិគ្រប់គ្រងចាត់ចែងថវិកាពីអង្គនីតិបញ្ញត្តិ ឬ ជាអង្គភាពដែលទទួលបានអាណត្តិកិច្ចច្បាស់លាស់ដើម្បីអនុវត្តសកម្មភាពការងារ រៀបចំ គ្រប់គ្រង និងត្រួតពិនិត្យការអនុវត្តថវិកា។

**អតិផរណា**
អ. inflation
បារ. inflation ( f. )

ការកើនឡើងនៃកម្រិតថ្លៃជាទូទៅរបស់ទំនិញនិងសេវាក្នុងប្រទេសឬតំបន់ ក្នុងរយៈពេលជាក់លាក់ណាមួយ។

**អតិផរណាជាថ្មី/បុនាតិផរណា**
អ. reinflation
បារ. réinflation ( f. )

ការកើនឡើងវិញនៃអត្រាអតិផរណា។

**អតិផរណាហួសហេតុ/អធិកផរណា**
អ. hyperinflation
បារ. hyperinflation ( f. )

ការកើនឡើងខ្លាំងហើយលឿនក្នុងរយៈពេលខ្លីដែលមិនអាចគ្រប់គ្រងបាននៃអត្រាអតិផរណា។

**អតិពលកម្ម**

អ. labor intensive

ដំណើរការ ឬ ឧស្សាហកម្មដែលទាមទារនូវចំនួនកម្លាំងពលកម្មដ៏ច្រើនទើបអាចផលិតទំនិញឬសេវាបាន។

ឧ. រាជរដ្ឋាភិបាលមានគោលបំណងជំរុញកែប្រែនិងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជាពីអតិពលកម្មទៅជាឧស្សាហកម្មផ្អែកលើជំនាញ។

**អតិរេក**

អ. surplus excess

បារ. surplus (m.)

អ្វីដែលលើសពីការកំណត់ ភាពច្រើនក្រៃ ភាពពិសេស ចំនួនបន្ថែម...។

ក្នុងន័យសេដ្ឋកិច្ច«អតិរេក»ប្រើសំដៅដល់ភាពលើសនៃចំនួន។

ឧ. បន្ទាប់ពីបានដាក់ឱ្យអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរួចមក រាជរដ្ឋាភិបាលសម្រេចបានជាមូលដ្ឋាននូវ«ភាពជឿទុកចិត្តនៃថវិកា»តាមរយៈការបង្កើនចំណូល និងការធ្វើវិចារណកម្មចំណាយ ជាពិសេសបង្កើនបាននូវអតិរេកនៃថវិកាជាតិដែលអនុញ្ញាតឱ្យបង្កើនទុនវិនិយោគសាធារណៈលើហេដ្ឋារចនាសម្ព័ន្ធសង្គមសេដ្ឋកិច្ចក្នុងគោលដៅពង្រឹងនិងពង្រីកសេវាសាធារណៈ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។

**អប្បផរណា/បរិត្តផរណា**
អ. deflation
បារ. déflation ( f. )

ការធ្លាក់ចុះនៃកម្រិតថ្លៃជាទូទៅរបស់ទំនិញនិងសេវា ក្នុងប្រទេសឬតំបន់ ក្នុងរយៈពេលជាក់លាក់ណាមួយ ក្នុងពេលដែលអត្រាអតិផរណាធ្លាក់ចុះក្រោមសូន្យភាគរយ។

**អប្បផរណាករ/ដេផ្លាទ័រ/បរិត្តផរណាករ**
អ. deflator
បារ. déflateur ( m. )

អត្រាអតិផរណាដែលប្រើជាតួចែកដើម្បីបំប្លែងថ្លៃទំនិញនិងសេវាពីចំនួនណូមីណាល់ទៅចំនួនពិត។

**អហេតុកភ័យ**
អ. panic
បារ. panique ( f. )

ការបាត់បង់ទំនុកចិត្តភ្លាមៗរបស់សាធារណជនលើប្រព័ន្ធហិរញ្ញវត្ថុ។
ឧ. អហេតុកភ័យនាំឱ្យធនាគារនិងក្រុមហ៊ុនអាជីវកម្មទទួលបរាជ័យ តម្លៃភាគហ៊ុនធ្លាក់ចុះ។

**អាករលើតម្លៃបន្ថែម (អ.ត.ប.)**
អ. value added tax ( VAT )
បារ. taxe sur la valeur ajoutée ( T.V.A. )

ពន្ធប្រយោលមួយប្រភេទដាក់លើទំនិញឬសេវាណាមួយនៅពេលដែលតម្លៃត្រូវបានបន្ថែមនៅគ្រប់ដំណាក់កាលនៃខ្សែចង្វាក់ផ្គត់ផ្គង់ពីចំណុចផលិតកម្មទៅដល់ចំណុចលក់។

**អាជីវករប្តូរប្រាក់**
អ. money changer

អ្នកប្រកបមុខរបរប្តូរប្រាក់ដែលមានអាជ្ញាបណ្ណ។

**អាហ្វីស**
អ. poster
បារ. affiche ( f. )

ផ្ទាំងបោះពុម្ពដែលបានរចនាឡើងជាអក្សរសុទ្ធ ឬជារូបភាពសុទ្ធឬក៏ជាអក្សរផងនិងរូបភាពផង សម្រាប់ដាក់ជាប់នឹងជញ្ជាំងឬនៅទីកន្លែងសាធារណៈ សម្រាប់ទាក់ទាញចំណាប់អារម្មណ៍អ្នកឆ្លងកាត់ ដើម្បីឱ្យដឹងអំពីគោលបំណងនៃអ្នកផ្សព្វផ្សាយ។

**អ្នកគ្រប់គ្រងផ្នែកលក់**
អ. sales manager
បារ. chef des ventes

អ្នកអនុវត្តយុទ្ធសាស្ត្រលក់ដោយកំណត់គោលដៅកម្រិតចំនួននៃការលក់ រៀបចំផែនការលក់ វិភាគទិន្នន័យ រៀបចំបណ្តុះបណ្តាលរបៀបលក់ កំណត់ទីតាំងលក់ និងត្រួតពិនិត្យសមាជិកក្រុមអ្នកលក់។

**អ្នកជាប់ពន្ធ**
អ. taxpayer
បារ. contribuable ( n. )

រូបវន្តបុគ្គលឬនីតិបុគ្គលដែលជាប់កាតព្វកិច្ចបង់ពន្ធជូនរដ្ឋ។

**អ្នកដំណើរការតតិយភាគី/ ប្រតិបត្តិករតតិយភាគី**
អ. third-party processor
បារ. processeur tiers

រូបវន្តបុគ្គលឬនីតិបុគ្គលដែលធនាគារបានប្រគល់សិទ្ធិឱ្យធ្វើប្រតិបត្តិការលើមួយឬច្រើនផ្នែកនៃសេវាប្រតិបត្តិការទូទាត់ប្រាក់របស់ធនាគារ។

**អ្នកត្រួតពិនិត្យផ្នែកលក់**
អ. sale supervisor
បារ. superviseur de vente

អ្នកទទួលខុសត្រូវបន្ទាប់ពីប្រធានផ្នែកលក់ ដែលទទួលបន្ទុកអនុវត្តផែនការលក់ និងគ្រប់គ្រងបុគ្គលិកផ្នែកលក់ក្នុងអង្គភាពអាជីវកម្ម។

**អ្នកសម្របសម្រួលផ្នែកលក់**
អ. sale coordinator
បារ. coordinateur de vente

អ្នកទទួលខុសត្រូវសម្របសម្រួលក្រុមអ្នកលក់ មានភារកិច្ចគ្រប់គ្រងពេលវេលាលក់ បំពេញឯកសារសំខាន់ៗ ផ្ដល់និងទទួលព័ត៌មានពាក់ព័ន្ធការលក់ និងដោះស្រាយបញ្ហានានាដែលកើតចេញពីអតិថិជន។

**អ្នកឯកទេសផ្នែកលក់**
អ. sale specialist
បារ. spécialiste de vente

អ្នកលក់ទំនិញផ្ទាល់ដែលមានចំណេះដឹងបច្ចេកទេសច្បាស់លាស់អំពីផលិតផល។

**ឥណទាន**
អ. credit
បារ. crédit ( m. )

១- វិធីដែលអ្នកខ្ចីទទួលបានប្រាក់ ទំនិញ ឬសេវាដោយយល់ព្រមទូទាត់សងជាមួយនឹងការប្រាក់តាមកាលបរិច្ឆេទដាក់លាក់នាពេលអនាគត។

២- ប្រាក់ ទំនិញ ឬសេវាសម្រាប់ឱ្យគេខ្ចីហើយដែលអ្នកខ្ចីយល់ព្រមទូទាត់សងជាមួយនឹងការប្រាក់តាមកាលបរិច្ឆេទដាក់លាក់នាពេលអនាគត។

**ឥណទាយក**
អ. creditor
បារ. créditeur (m.)

បុគ្គលដែលមានឥណទានក្នុងគណនីណាមួយ។ (បច្ចេកសព្ទធនាគារ)

**ឧត្តមភាពដាច់ខាត**
អ. absolute advantage
បារ. avantage absolu

សមត្ថភាពរបស់ប្រទេស ក្រុមហ៊ុន ឬ បុគ្គល ក្នុងការផលិតទំនិញឬសេវា ដែលមានថ្លៃដើមផលិតកម្មទាបជាងប្រទេស ក្រុមហ៊ុន ឬ បុគ្គលផ្សេងទៀត។

ឧ. សហរដ្ឋអាម៉េរិកមានឧត្តមភាពដាច់ខាតក្នុងការផលិតប្រេង ពីព្រោះសហរដ្ឋអាម៉េរិកមានសមត្ថភាពផលិតប្រេងដែលមានថ្លៃដើមទាបជាងប្រទេសម៉ិកស៊ិក។

**ឧត្តមភាពប្រកួតប្រជែង**
អ. competitive advantage
បារ. avantage compétitif

សមត្ថភាពរបស់ប្រទេស ក្រុមហ៊ុន ឬ បុគ្គល ដែលមានប្រៀបឈ្នះលើគូប្រកួតប្រជែង ក្នុងការជ្រៀតចូលទីផ្សារ បង្កើនទំហំលក់ បង្កើនប្រាក់ចំណេញ និងរក្សាអតិថិជនបានច្រើនជាងគូប្រកួតប្រជែង។

ឧត្តមភាពបែបនេះអាចសម្រេចបានតាមរយៈរចនាសម្ព័ន្ធ ថ្លៃដើម គុណភាព សោភណភាពផលិតផល ប្រព័ន្ធចែកចាយ និងការគាំទ្ររបស់អតិថិជន។

ឧ. ប្រទេសវៀតណាមមានឧត្តមភាពប្រកួតប្រជែងលើការនាំចេញអង្ករទៅកាន់ទីផ្សារអង្ករពិភពលោក ពីព្រោះអង្ករវៀតណាមមានថ្លៃដើមផលិតកម្មទាប ការវេចខ្ចប់ល្អ និងកេរ្តិ៍ឈ្មោះនៅលើទីផ្សារអង្ករពិភពលោក។

**ឧត្តមភាពប្រៀបធៀប**

អ. comparative advantage

បារ. avantage comparé

សមត្ថភាពរបស់ប្រទេស ក្រុមហ៊ុន ឬ បុគ្គល ក្នុងការផលិតទំនិញឬសេវាដែលមានថ្លៃដើមកាលានុវត្តភាពទាបជាងប្រទេស ក្រុមហ៊ុន ឬ បុគ្គលផ្សេងទៀត។

ឧត្តមភាពប្រៀបធៀបផ្តល់លទ្ធភាពឱ្យក្រុមហ៊ុនលក់ទំនិញឬសេវាក្នុងតម្លៃទាប ជាងគូប្រជែងរបស់ខ្លួន និងទទួលបានប្រាក់ចំណេញកម្រិតខ្ពស់។

ឧ. ប្រទេសកម្ពុជាមានឧត្តមភាពប្រៀបធៀបក្នុងការផលិតអង្ករសរីរាង្គជាងប្រទេសកូវ៉ែត។

**ឧបត្ថម្ភធន**

អ. subsidy

បារ. subvention ( f. )

ធនធានដែលរដ្ឋាភិបាលផ្តល់ឱ្យស្ថាប័ន ក្រុម ឬ បុគ្គល ជាទូទៅក្នុងរូបភាពជាហិរញ្ញប្បទាននិង/ឬការអនុគ្រោះពន្ធ ដើម្បីលើកកម្ពស់សមត្ថភាពប្រកួតប្រជែង សុខុមាលភាពសង្គម ឬ ផលប្រយោជន៍សាធារណៈ។

ឧ. រាជរដ្ឋាភិបាលបានផ្តល់ឧបត្ថម្ភធនតាមរយៈ

ការលើកលែងពន្ធនាំចូលជីកសិកម្ម ដើម្បីជួយសម្រាលបន្ទុកកសិករ។

**ឯកទេសនីយកម្ម**

អ. specialization

បារ. spécialisation ( f. )

យន្តការ ឬ សកម្មភាពដែលនាំឱ្យឈានទៅដល់ចំណេះដឹង ជំនាញ វិធីសាស្ត្រ ឬ បច្ចេកទេសក្នុងការផលិតផលិតផលជាក់លាក់មួយ ដែលមានប្រសិទ្ធភាពផលិតខ្ពស់ជាងមុន។

ឧ. រាជរដ្ឋាភិបាលនឹងបន្តជំរុញការធ្វើឯកទេសនីយកម្មដែលផ្អែកលើការអភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សំដៅបង្កើនប្រសិទ្ធភាពផលិត និងការប្រកួតប្រជែង។